# គោលនយោបាយ

គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ

LEAGUE FOR DEMOCRACY PARTY

## គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ

www.camldp.org

# មាតិកា

បុព្វកថា ........................................................................................ 1

គោលដៅ ......................................................................................... 4

ចំណុចចាប់ផ្តើម ................................................................................ 8

១. ការផ្លាស់ប្តូរផ្នត់គំនិតប្រជាពលរដ្ឋអំពីកិច្ចបដិបត្តិព្រះធម៌..................8

២. ការផ្លាស់ប្តូរផ្នត់គំនិតប្រជាពលរដ្ឋអំពីសីលធម៌សង្គម....................12

៣. ការផ្លាស់ប្តូរផ្នត់គំនិតប្រជាពលរដ្ឋអំពីប្រជាធិបតេយ្យ/នយោបាយ ...15

យន្តការប្រាំបីចំណុច ......................................................................... 23

១. កំណាត់អាណត្តិនាយករដ្ឋមន្ត្រីត្រឹមពីរអាណត្តិ ............................ 23

២. មិនអនុញ្ញាតឲ្យនាយករដ្ឋមន្ត្រីបង្កើតក្រុមអង្គរក្សដោយខ្លួនឯង........27

៣. តម្រូវឲ្យនាយករដ្ឋមន្ត្រីរស់នៅក្នុងនិវេសនដ្ឋានរដ្ឋ ........................28

៤. បង្កើតតុលាការរដ្ឋបាល..............................................................29

៥.ឋានន្តរសក្តិចាប់ពីឧត្តមសេនីយ៍យោធា និងនគរបាលត្រូវសុំសេចក្តីទុកចិត្តពី សភា.........................................................................31

៦. អព្យាក្រឹតមន្ត្រីរាជការ ...........................................................32

៧. បោះឆ្នោតជ្រើសរើស និងបោះឆ្នោតដកតំណាងគ្រប់លំដាប់ - ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ ខេត្ត/រាជធានី - ដោយប្រជាពលរដ្ឋផ្ទាល់34

៨. បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រតាមប្រព័ន្ធចម្រុះ......................36

*គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ*

ឥរិយាបថនយោបាយ........................................................................ 46

ធនធានមនុស្ស.................................................................................... 55

# បុព្វកថា

- ដោយមើលឃើញថា គម្លាតនៃជីវភាពរស់នៅក្នុងចំណោមប្រជាពលរដ្ឋកាន់តែរីកធំទៅៗដែលគំរាមកំហែងដល់ស្ថេរភាពសេដ្ឋកិច្ច នយោបាយ និងសន្តិសុខជាតិ ទោះបីជាប្រទេសកម្ពុជាមានការរីកចម្រើនខាងផ្នែកសម្ភារៈរូបវន្ត និងហេដ្ឋារចនាសម្ព័ន្ធ ជាងពេលណាៗទាំងអស់ក្នុងប្រវត្តិសាស្ត្រកម្ពុជាក៏ដោយ
- ដោយមើលឃើញថា មន្ត្រីរាជការគ្រប់លំដាប់ដែលជាភ្នាក់ងាររបស់រដ្ឋបានក្លាយជាឧបករណ៍នយោបាយបម្រើគណបក្សកាន់អំណាច ហើយរួមចំណែកយ៉ាងសកម្ម ធ្វើឲ្យរដ្ឋាភិបាលអសមត្ថភាព និងគ្មានការទទួលខុសត្រូវក្នុងការផ្តល់សេវាសង្គមជូនប្រជាពលរដ្ឋដែលជាម្ចាស់ប្រទេសឲ្យបានស្មើភាពគ្នានៅចំពោះមុខច្បាប់
- ដោយមើលឃើញថា របៀបនៃការធ្វើនយោបាយរបស់គណបក្សនយោបាយបច្ចុប្បន្នបានបង្កើតវប្បធម៌ថ្មីនៃការបែងចែងបក្ខពួកក្នុងសង្គមក្នុងចំណោមប្រជាពលរដ្ឋទូទៅ ទាំងព្រះសង្ឃ មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ និងបានធ្វើឲ្យសាមគ្គីភាព និងទំនុកចិត្តរវាងប្រជាពលរដ្ឋកំពុងធ្លាក់ចុះយ៉ាងខ្លាំង
- ដោយមើលឃើញថា ការគិតតែប្រយោជន៍ផ្ទាល់ខ្លួនរបស់ប្រជាពលរដ្ឋធ្វើឲ្យសីលធម៌សង្គមបាន និងកំពុងធ្លាក់ចុះយ៉ាងគំហុក ជាពិសេសពាក់ព័ន្ធទៅនឹងសុចរិតភាព និងការទទួលខុសត្រូវចំពោះទង្វើរបស់ប្រជាពលរដ្ឋម្នាក់ៗ ក្នុងក្របខ័ណ្ឌជាសមាជិកគ្រួសារ និងជាប្រជាពលរដ្ឋម្នាក់នៃប្រទេសជាតិមួយ

- ដោយមើលឃើញថា ភាពអយុត្តិធម៌ក្នុងប្រព័ន្ធតុលាការក្នុងការដោះស្រាយបញ្ហាប្រជាពលរដ្ឋបណ្តាលឲ្យមនុស្សទន់ខ្សោយ និងគ្មានទីពឹងត្រូវទទួលរងការចាញ់ក្តីទាំងបំពាន និងច្បាស់ក្រឡែត ដោយអំណាចទឹកប្រាក់របស់អ្នកមានទ្រព្យសម្បត្តិ និងអ្នកមានអំណាច

- ដោយមើលឃើញថា ប្រទេសកម្ពុជាកំពុងតែស្ថិតនៅក្រោមការគំរាមកំហែងយ៉ាងពិតប្រាកដដែលអាចនឹងឈានដល់ការបាត់បង់ទឹកដី និងជាតិសាសន៍ពីសំណាក់ប្រទេសជិតខាងក្នុងរូបភាពថ្មីនៃការលេបត្របាក់ទឹកដីគឺ "ការដាក់ថ្នាំបន្ទន់ឆ្អឹង រួចលេបទាំងរស់"

- ដោយយល់ឃើញថា បញ្ហាទាំងអស់ដូចបានរៀបរាប់ខាងលើនេះកើតចេញពីការគ្រប់គ្រងប្រទេស ដោយប្រព័ន្ធដែលប្រមូលផ្តុំអំណាចទៅលើបុគ្គលតែម្នាក់ ឬមួយក្រុមតូច ឬដោយការគ្រប់គ្រងតាមឆន្ទៈរបស់មេដឹកនាំ និងការស៊ុមគ្រលុំគ្នា ជាជាងតាមប្រព័ន្ធច្បាប់ដែលមានតម្លាភាពប្រសិទ្ធភាព និងការទទួលខុសត្រូវ

- ដោយយល់ឃើញថា ការដឹកនាំតាមប្រព័ន្ធដែលប្រមូលផ្តុំអំណាច និងការស៊ុមគ្រលុំនឹងនៅតែបន្តពីមួយជំនាន់ទៅមួយជំនាន់ទៀត ដោយសារតែភាពអសកម្មរបស់ប្រជាពលរដ្ឋភាគច្រើនក្នុងការមិនចូលរួមក្នុងចលនានយោបាយ និងមួយចំនួនទៀតចូលរួមដោយគ្មានការយល់ដឹង

- ដោយយល់ឃើញថា មានតែការផ្លាស់ប្តូរផ្នត់គំនិតប្រជាពលរដ្ឋឲ្យយល់ត្រូវលើគោលធំៗបី គឺកិច្ចបដិបត្តិព្រះធម៌ សីលធម៌សង្គម និងប្រជាធិបតេយ្យ/នយោបាយ (ការផ្លាស់ប្តូរប្រព័ន្ធដឹកនាំរដ្ឋពីប្រព័ន្ធដែលប្រមូលផ្តុំអំណាចមកជាការដឹកនាំដោយប្រព័ន្ធដែលពង្រាយអំណាចដោយការ អនុវត្តច្បាប់

កើតចេញពីយន្តការប្រាំបីចំណុច ច) ទើបអាចដោះស្រាយបញ្ហាទាំងអស់ខាងលើបាន

- ដោយយល់ឃើញថា មានតែសកម្មភាពនយោបាយប្រកបដោយទស្សនវិស័យ និងប្រាសចាកភាពអាត្មានិយមប៉ុណ្ណោះ ទើបអាចផ្តល់ជម្រើសសន្តិវិធីឲ្យប្រជាពលរដ្ឋឲ្យគាំទ្រចលនានយោបាយដើម្បីទាមទារយកសិទ្ធិ និងអំណាចរបស់ខ្លួនដោយស្របច្បាប់ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ (គ.ស.ប) **[League for Democracy Party (LDP)]** ត្រូវបានបង្កើតឡើង និងទទួល ស្គាល់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃលេខ ៧៩១ ប្រ.ក ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០០៦

គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យមានអត្តសញ្ញាណសម្គាល់ចំនួនបួន **(១)គោលដៅ (២)ចំណុចចាប់ផ្តើម (៣)ឥរិយាបថនយោបាយ និង (៤)ធនធានមនុស្ស**

# ១
# គោលដៅ

គោលដៅរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យគឺ **"មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់"** ដែលនឹងត្រូវសម្រេចតាមរយៈ "ការផ្លាស់ប្តូរផ្នត់គំនិតរបស់ប្រជាពលរដ្ឋលើគោលធំៗបី" នៅដំណាក់កាលដំបូង និង "ការប្រែក្លាយយន្តការប្រាំបីចំណុ ចឲ្យទៅជាច្បាប់" នៅដំណាក់កាលបន្ទាប់។

គោលដៅរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យក្តោបអត្ថន័យពីរសំខាន់ដែលឆ្លុះបញ្ចាំងបញ្ហាសង្គមខ្មែរ។ ទីមួយ គឺសំដៅលើអត្ថន័យរបស់ពាក្យ **"ស្មើភាពគ្នា"**។ ប្រជាពលរដ្ឋខ្មែរតាំងតែពីដើមរៀងមកមិនធ្លាប់បានរស់នៅដោយស្មើភាពគ្នានោះទេ មិនថាស្មើភាពគ្នាខាងឱកាសអភិវឌ្ឍន៍ខ្លួន ការទទួលសេវាសង្គម ឬនៅចំពោះមុខច្បាប់នោះទេ។ ប្រជាពលរដ្ឋខ្មែរបាន និងកំពុងចូលរួមក្នុងសកម្មភាពនយោបាយដោយគ្មានការយល់ដឹង និងគ្មានគោលដៅច្បាស់លាស់។ លទ្ធផលនៃការចូលរួមបែបនេះគឺបានត្រឹមតែជួយអ្នកនយោបាយទាំងនោះទៅបង្កើតសង្គមកម្ពុជាដែលមានវណ្ណៈអ្នកដឹកនាំដែលពីមុនមានរូបភាពជាការដឹកនាំដោយស្តេច និងបច្ចុប្បន្នមានរូបភាពជាប្រជាធិបតេយ្យ តែជាតុពិតគឺការប្រមូលផ្តុំអំណាច បើទោះបីជានៅមានស្តេចសោយរាជ្យនៅឡើយក្តី។ វណ្ណៈមួយទៀតគឺវណ្ណៈត្រូវបានគេដឹកនាំដែលសំដៅទៅលើប្រជាពលរដ្ឋទូទៅ ដែលជាម្ចាស់ប្រទេសដោយសារតែពួកគាត់បាត់បង់ភាពជាម្ចាស់អំណាច ជាអ្នកគ្មានទ្រព្យសម្បត្តិ និងគ្មានចំណេះដឹង។

ដោយសារតែ ប្រជាពលរដ្ឋសុខចិត្តទ្រាំរស់នៅដោយមានវណ្ណៈពីរយ៉ាងដូច្នេះទើបវណ្ណៈដែលត្រូវបានគេដឹកនាំកំពុងរស់នៅដោយមិនស្មើមុខស្មើមាត់នឹងវណ្ណៈ

ដឹកនាំនៅក្នុងទឹកដីសុវណ្ណភូមិរបស់ខ្លួន។ លើសពីនេះទៀត ការរស់នៅដោយមានគម្លាតខ្លាំងហួស ហេតុក្នុងជីវភាពរស់នៅរវាងវណ្ណៈទាំងពីរធ្វើឲ្យកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសក្រីក្របំផុត ពុករលួយបំផុត និងអពមង្គលបំផុតនៅលើពិភពលោក ដោយឈរលើសូចនាករអន្តរជាតិរបស់អង្គការសហប្រជាជាតិ យូអិនឌីភី (UNDP) សម្រាប់សន្ទស្សន៍អភិវឌ្ឍន៍ធនធានមនុស្ស និងអង្គការតម្លាភាពអន្តរជាតិ (Transparency International) សម្រាប់អំពីពុករលួយ ឆ្នាំ២០១២។

វណ្ណៈត្រូវបានគេដឹកនាំតស៊ូរស់នៅដើម្បីតែកំដរវណ្ណៈដឹកនាំតែប៉ុណ្ណោះ ដោយសារតែពួកគាត់គ្មានចំណេះវិជ្ជាជ្រៅជ្រះ គ្មានទ្រព្យសម្បត្តិ និងគ្មានអំណាចប្រើប្រាស់សិទ្ធិជាម្ចាស់ប្រទេសដែលជាឧបករណ៍ជីវិតអាចជួយឲ្យពួកគាត់ចូលរួមប្រកួតប្រជែងដោយស្មើភាពគ្នានៅចំពោះមុខច្បាប់ក្នុងប្រទេសមួយដែលមានពួកគាត់ជាម្ចាស់។ ប្រជាពលរដ្ឋអាចនឹងរស់នៅក្នុងសង្គមស្មើភាពគ្នា តែនៅពេលណាដែលប្រជាពលរដ្ឋចូលរួមបង្កើតសង្គមស្មើភាពគ្នា ដោយកណ្ដាប់ដៃខ្លួនឯង តាមរយៈសកម្មភាពសង្គម និងសកម្មភាពនយោបាយតែប៉ុណ្ណោះ។ គួរកត់សម្គាល់ថា សង្គមស្មើភាពគ្នាគឺជាសង្គមដែលប្រជាពលរដ្ឋមានឱកាស និងការទទួលខុសត្រូវនៅចំពោះមុខច្បាប់ស្មើៗគ្នាដើម្បីបំពេញកិច្ចការចិញ្ចឹមជីវិត ហើយទទួលផលដូចគ្នា ឬខុសៗគ្នា អាស្រ័យទៅលើកម្លាំង (កាយ បញ្ញា ថវិកា) និងការខិតខំប្រឹងប្រែងរបស់បុគ្គលម្នាក់ៗ ដូចប្រជាពលរដ្ឋនៅក្នុងប្រទេសអភិវឌ្ឍន៍ដទៃទៀត។

អត្ថន័យទីពីរនៃគោលដៅរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យគឺ "**ការរស់នៅក្នុងភាពជាម្ចាស់**"។ ជាក់ស្ដែង ប្រជាពលរដ្ឋខ្មែរទូទៅមិនធ្លាប់ចាត់ទុកខ្លួន

ឯងជាម្ចាស់ប្រទេសនោះទេ ទោះបីជាម្ចាស់តាមផ្លូវធម្មជាតិដែលខ្លួនកើតលើទឹកដីនេះ ឬម្ចាស់តាមផ្លូវច្បាប់ដែលធានាដោយរដ្ឋធម្មនុញ្ញក៏ដោយ។ ជាទូទៅប្រជាពលរដ្ឋយល់ឃើញថា រដ្ឋាភិបាលគឺជាម្ចាស់ប្រទេស និងជាអ្នកទទួលខុសត្រូវចំពោះកិច្ចការស្រុកទេសសព្វបែបយ៉ាង។ ប្រជាពលរដ្ឋចាត់ទុកខ្លួនឯងថាពួកគាត់គ្រាន់តែជាមនុស្សកើត និងរស់នៅលើទឹកដីនេះតែប៉ុណ្ណោះ ហើយពួកគាត់យល់ឃើញថា ពួកគាត់គ្មានកាតព្វកិច្ច និងការទទួលខុសត្រូវអ្វីទាំងអស់ចំពោះកិច្ចការស្រុកទេស។ ប្រជាពលរដ្ឋតស៊ូប្តូរផ្តាច់តែដើម្បីការការពារ និងការរីកចម្រើនក្នុងគ្រួសារដែលពួកគាត់ដឹងយ៉ាងច្បាស់ថា ពួកគាត់គឺជាម្ចាស់ និងជាអ្នកទទួលខុសត្រូវ។

ផ្ទុយពីភាពជាម្ចាស់លើគ្រួសារ ប្រជាពលរដ្ឋមិនយល់អំពីអត្ថន័យនៃភាពជាម្ចាស់ និងកាតព្វកិច្ចរបស់ពួកគាត់ក្នុងនាមជាប្រជាពលរដ្ឋ ដែលជាម្ចាស់មាតុភូមិទេ។ ទោះបីជាពួកគាត់បានចូលរួមក្នុងចលនារំដោះជាតិ ឬអភិវឌ្ឍជាតិកន្លងមកក៏ដោយ ក៏ការចូលរួមរបស់ពួកគាត់មានលក្ខណៈជាការគាបសង្កត់ ការបង្ខិតបង្ខំ ការភ័យខ្លាច ឬដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនតែប៉ុណ្ណោះ។ ដោយសារតែបុព្វហេតុនៃការចូលរួមគ្មានភាពជាម្ចាស់ និងការទទួលខុសត្រូវក្នុងភាពជាម្ចាស់ ប្រជាពលរដ្ឋមិនមានមោទនភាព តម្លៃ និងកិត្តិយសក្នុងចលនារំដោះជាតិ ឬអភិវឌ្ឍជាតិឲ្យសមនឹងការចូលរួម និងការលះបង់របស់ពួកគាត់ឡើយ។ ភាពជាម្ចាស់ក៏មិនអាចកើតឡើងបានដែរ ដរាបណាប្រជាពលរដ្ឋមិនបានចូលរួមដោយការយល់ដឹង និងការទទួលខុសត្រូវដើម្បីបង្កើតសង្គមនោះដោយកណ្តាប់ដៃខ្លួនឯងតាមមធ្យោបាយទាំងឡាយដែលធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់កម្ពុជា។

ដើម្បីកៀងគរកម្លាំងប្រជាពលរដ្ឋឲ្យចូលរួម ក្នុងសកម្មភាពនយោបាយជាមួយគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យទៅសម្រេចគោលដៅ "មាតុភូមិមួយដែលពួកយើងរស់នៅដោយភាពស្មើគ្នាក្នុងភាពជាម្ចាស់" គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យបាន និងកំពុងពន្យល់ប្រជាពលរដ្ឋឲ្យស្គាល់តម្លៃពិតប្រាកដរបស់ប្រជាពលរដ្ឋដែលជាម្ចាស់ប្រទេសជាអចិន្ត្រៃយ៍ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋក្នុងការចូលរួមក្នុងសកម្មភាពសង្គម ជាពិសេសសកម្មភាពនយោបាយដើម្បីឲ្យខ្លួនមានឱកាសដូចគ្នាទៅបង្កើតសង្គមមួយ ដែលប្រជាពលរដ្ឋទូទៅអាចរស់នៅដោយស្មើភាពគ្នាផង និងក្នុងភាពជាម្ចាស់ផង។ នៅពេលកម្ពុជាបានក្លាយជាប្រទេសមួយដែលប្រជាពលរដ្ឋរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់ ប្រជាពលរដ្ឋខ្មែរនឹងរស់នៅដោយមានមោទនភាព និងភាពថ្លៃថ្នូរពិតប្រាកដ សមជាខ្មែរម្ចាស់កេរ្តិ៍អង្គរ ប្រហាក់ប្រហែលទៅនឹងប្រជាពលរដ្ឋនៅក្នុងបណ្តាអារ្យប្រទេសផ្សេងៗទៀត។

## ២
## ចំណុចចាប់ផ្តើម

ដើម្បីឈានទៅសម្រេចគោលដៅ "មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់" គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យចាប់ផ្តើមសកម្មភាពនយោបាយរបស់ខ្លួនចេញពីការពន្យល់ប្រជាពលរដ្ឋអំពីកិច្ចបដិបត្តិព្រះធម៌ សីលធម៌សង្គម និងនយោបាយ/ប្រជាធិបតេយ្យ (របៀបនៃការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងរដ្ឋដែលប្រមូលផ្តុំអំណាចមកជាការគ្រប់គ្រងរដ្ឋដោយប្រព័ន្ធ ដែលពង្រាយអំណាចដែលមានប្រជាពលរដ្ឋជាម្ចាស់តាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់ក្រោមជាតិតាមរយៈការប្រែក្លាយយន្តការប្រាំបីចំណុ ចឲ្យទៅជាច្បាប់)។

### ការពន្យល់អំពីការផ្លាស់ប្តូរផ្នត់គំនិតលើគោលធំៗបី

ការផ្លាស់ប្តូរផ្នត់គំនិតប្រជាពលរដ្ឋលើគោលធំៗបី ៖ កិច្ចបដិបត្តិព្រះធម៌ សីលធម៌សង្គម និងប្រជាធិបតេយ្យ គឺជាបេសកកម្មអាទិភាព និងជាអចិន្ត្រៃយ៍របស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យដើម្បីឲ្យប្រជាពលរដ្ឋខ្មែរក្លាយជាប្រជាពលរដ្ឋដែលសកម្ម ថ្លៃថ្នូរ និងទទួលខុសត្រូវចំពោះកិច្ចការប្រទេសជាតិជាប់ជាប្រចាំ ដូចជាប្រជាពលរដ្ឋនៅក្នុងអារ្យប្រទេសផ្សេងទៀត។

### ១. ការផ្លាស់ប្តូរផ្នត់គំនិតប្រជាពលរដ្ឋអំពីកិច្ចបដិបត្តិព្រះធម៌

ព្រះធម៌គឺជាមេរៀនត្រាស់ដឹងរបស់ព្រះពុទ្ធ ប៉ុន្តែការប្រើប្រាស់ព្រះធម៌ត្រឹមតែជាសាសនា ឬជំនឿប្រាសចាកហេតុផល តាមរយៈពាក្យ "បុណ្យ" ឬ"ធ្វើបុណ្យ" ដូចសព្វថ្ងៃនេះ កំពុងតែនាំប្រជាពលរដ្ឋខ្មែរឲ្យលិចលិប និងលង់លក់ក្នុងការបដិបត្តិដែលមិនត្រឹមតែគ្មានប្រយោជន៍នោះទេ ថែមទាំងបំផ្លាញអ្នកបដិបត្តិ ទាំង

សម្ភារៈ និងស្មារតីទៀតផង។ អ្វីដែលធម្មកថិកផ្សព្វផ្សាយតាមរោងបុណ្យ ពិធីបុណ្យ ឬរលកធាតុអាកាសដើម្បីនាំប្រជាពលរដ្ឋឲ្យធ្វើបុណ្យរាល់ថ្ងៃនេះគឺភាគច្រើន មានលក្ខណៈជាសាសនា និង/ឬជំនឿក្នុងចេតនាដើម្បីទាញយកប្រយោជន៍ផ្ទាល់ខ្លួនរបស់គេជាអ្នកដឹកនាំពិធីទាំងនោះ។ ចំណែកពុទ្ធបរិស័ទត្រូវបានធម្មកថិកធ្វើឲ្យមានជំនឿថា ពួកគាត់នឹងទទួលផលនៅអនាគតជាតិ ពីទង្វើបច្ចុប្បន្នរបស់គេដែលផ្ទុយពីខ្លឹមសារបង្រៀនរបស់ព្រះសម្មាសម្ពុទ្ធដែលមានពុទ្ធដីកាថា ទង្វើដែលរកប្រយោជន៍សម្រាប់បច្ចុប្បន្នមិនបាន ក៏រកប្រយោជន៍សម្រាប់អនាគតមិនបាននោះដែរ (ឥធតប្បតិ បេច្ចតប្បតិ ឥធនន្ទតិ បេច្ចនន្ទតិ)។

ការប្រើប្រាស់ព្រះធម៌ត្រឹមតែជាជំនឿសាសនាដែលមានលក្ខណៈជាការបួងសួងបន់ស្រន់ និងឧទ្ទិសយ៉ាងដូច្នេះ គឺជាហេតុនាំឲ្យមានការធ្លាក់ចុះនូវអារ្យធម៌រុងរឿង និងទំនៀមទម្លាប់ថ្លៃថ្នូររបស់ខ្មែរ និងបាត់បង់ជាបន្តបន្ទាប់រហូតដល់មានការប្រល័យពូជសាសន៍អស់ជីវិតប្រជាពលរដ្ឋខ្មែរស្លូតត្រង់រាប់លាននាក់ និងការរីករាលដាលយ៉ាងពេញទំហឹងនៃទង្វើប្រាថ្នាផលប្រយោជន៍ផ្ទាល់ខ្លួនដែលជារឿយៗនៅលើគំនរទុក្ខសោករបស់ប្រជាពលរដ្ឋរួមឈាមខ្មែរផ្សេងទៀត។ ទង្វើអសីលធម៌ និងគំនិតអាត្មានិយមនេះកំពុងតែបន្តរីករាលដាលក្នុងចំណោមប្រជាពលរដ្ឋខ្មែរជាទូទៅគួរឲ្យព្រួយបារម្ភដោយសារតែការទេសនារបស់ធម្មកថិកប្រវ័ញ្ចលាភ នាំប្រជាពលរដ្ឋឲ្យដេកត្រាំងើបលែងរួចក្នុងជំនឿសាសនា។

មេរៀនត្រាស់ដឹងរបស់ព្រះពុទ្ធមានច្រើនអនេក ប៉ុន្តែព្រះអង្គបានបង្រៀនមនុស្សលោកនូវមេរៀនត្រាស់ដឹងតែមួយចំនួនតូចដែលមានប្រយោជន៍សម្រាប់

អ្នកសិក្សាដើម្បីបដិបត្តិរកសេចក្តីសុខនៅក្នុងជីវិតបច្ចុប្បន្ន។ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យជ្រើសរើសមេរៀនដែលព្រះពុទ្ធបានបង្រៀនមួយចំនួន ដែលយើងយល់ថាមានសារប្រយោជន៍ ជាពិសេសមេរៀនទាក់ទងទៅនឹងការវៀរចាកមិនប្រព្រឹត្តអំពីអាក្រក់ (សព្វបាបស្សអករណំ) និងការប្រព្រឹត្តតែអំពីល្អ (កុសលស្សូបសម្បទា) មកធ្វើជាមូលដ្ឋានគ្រឹះសម្រាប់សកម្មភាពពន្យល់ប្រជាពលរដ្ឋឲ្យមានការផ្លាស់ប្តូរផ្នត់គំនិតអំពីជីវិត និងការគិតតែប្រយោជន៍បុគ្គលមកជាការគិតប្រយោជន៍រួមដើម្បីឲ្យមានការចូលរួមដោយទឹកចិត្ត និងការយល់ដឹងក្នុងសកម្មភាពនយោបាយជាមួយគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ និងដើម្បីឈានទៅបង្កើតសង្គមប្រជាធិបតេយ្យ តាមកម្លាំង និងការទទួលខុសត្រូវរៀងៗខ្លួន ក្នុងនាមជាប្រជាពលរដ្ឋម្ចាស់ប្រទេសដែលមានប្រវត្តិសាស្ត្រធ្លាប់ល្បីរន្ទឺកាលពីអតីតកាល។

ដើម្បីឲ្យប្រជាពលរដ្ឋផ្លាស់ប្តូរផ្នត់គំនិតលើកិច្ចបដិបត្តិព្រះធម៌ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យបាន និងកំពុងពន្យល់ប្រជាពលរដ្ឋអំពី ៖

- ភាពខុសគ្នាជាសារវន្តរវាងព្រះធម៌ និងទំនៀមទម្លាប់ សាសនា ជំនឿ ដើម្បីឲ្យប្រជាពលរដ្ឋមានការយល់ដឹង និងបុព្វហេតុច្បាស់លាស់សម្រាប់ប្រព្រឹត្តទង្វើដែលជាកុសលសម្រាប់ខ្លួនឯងផង និងសម្រាប់ជនរួមឈាមខ្មែរទាំងមូលផង
- តួនាទីដ៏សំខាន់របស់ប្រជាពលរដ្ឋ ក្នុងការចូលរួមបញ្ចប់ការចាត់ទុកព្រះធម៌ជាជំនឿសាសនា សម្រាប់ការសម្បូងសង្រូងសុំសេចក្តីសុខសម្រាប់ជាតិក្រោយ ឬការឧទ្ទិស និងបួងសួងទៅដល់អ្នកដែលបានស្លាប់ហើយមកជាកិច្ចបដិបត្តិដោយការយល់ដឹង ដើម្បីឲ្យពួកគាត់រក

បានប្រយោជន៍ពីកិច្ចបដិបត្តិរបស់ពួកគាត់ សម្រាប់បច្ចុប្បន្នជាតិទាំងអស់គ្នា

- ដំណើរនៃជីវិត ជាពិសេសទាក់ទងទៅនឹងវដ្តនៃការស្លាប់ និងការកកើតជីវិតសាជាថ្មីដើម្បីឲ្យប្រជាពលរដ្ឋប្រកាន់យកទម្លាប់រស់នៅស្របទៅតាមច្បាប់ធម្មជាតិដែលនាំទៅរកការរីកចម្រើន
- ឧទាហរណ៍ជាក់ស្តែងផ្សេងៗនៃសេចក្តីសុខបច្ចុប្បន្នដែលកើតចេញពីកិច្ចបដិបត្តិព្រះធម៌ (ការធ្វើបុណ្យទីភ្លឺ និងប្រាសចាកភាពអាត្មានិយម) និងការខាតបង់សម្ភារៈទាំងបច្ចុប្បន្ន និងអនាគតដែលកើតចេញពីការអនុវត្តជំនឿសាសនា (ការធ្វើបុណ្យទីងងឹតភ្ជាប់ទៅនឹងប្រយោជន៍ផ្ទាល់ខ្លួន)
- ភាពខុសគ្នារវាងទង្វើណាជាទង្វើបុណ្យ និងទង្វើណាជាទង្វើបាប ហើយហ៊ានក្រោកឡើងកម្ចាត់អំពើអាក្រក់ដែលបានពួនសម្ងំបំផ្លាញព្រះធម៌ និងប្រយោជន៍ប្រជាពលរដ្ឋខ្លួនឯងជាយូរមកហើយ
- របៀបនៃការទាញយកផលប្រយោជន៍ពីកិច្ចបដិបត្តិព្រះធម៌ដើម្បីប្រែក្លាយខ្លួនឲ្យទៅជាប្រជាពលរដ្ឋថ្លៃថ្នូរ មានតម្លៃពិតប្រាកដ ទាំងនៅក្នុងគ្រួសារ សហគមន៍ និងប្រទេសជាតិសមជាខ្មែរម្ចាស់កេរ្តិ៍អង្គរ
- ទំនាក់ទំនងដែលមិនអាចកាត់ផ្តាច់គ្នាបានរវាងព្រះធម៌ សីលធម៌ សង្គម និងនយោបាយដើម្បីឲ្យប្រជាពលរដ្ឋមានសទ្ធាជ្រះថ្លាចូលរួមក្នុងសកម្មភាពនយោបាយ ប្រាសចាកភាពអាត្មានិយមដែលជាទង្វើចម្រើន "បុណ្យ" ជាងទង្វើណាៗទាំងអស់

*ការបកស្រាយលម្អិតនៃចំណុចនីមួយៗខាងលើនេះមាននៅក្នុងសារ សំឡេងដែលអាចរកបាននៅទីស្នាក់ការគណបក្សសម្ព័ន្ធដើម្បី ប្រជាធិបតេយ្យ ឬគេហទំព័រ ៖ www.camldp.org ។*

ព្រះធម៌គឺជាចលករដ៏មានសក្តានុពលសម្រាប់អភិវឌ្ឍប្រទេសជាតិ ប៉ុន្តែដើម្បីទាញយកប្រយោជន៍ពីកិច្ចបដិបត្តិព្រះធម៌ ប្រជាពលរដ្ឋត្រូវតែផ្លាស់ប្តូរផ្នត់គំនិតរបស់ខ្លួនពីការអនុវត្តបែបជំនឿ ដើម្បីជាតិក្រោយមកជាការសិក្សាស្វែងយល់រកហេតុផលសម្រាប់ជីវិតរស់នៅក្នុងពេលបច្ចុប្បន្ន។ ផ្អែកលើស្ថានភាពបច្ចុប្បន្នរបស់ប្រទេសជាតិ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យយល់ឃើញថាគ្មានទង្វើណាដែលធ្វើឲ្យចម្រើន "បុណ្យ" បានច្រើនជាងទង្វើជួយសង្គ្រោះប្រជាពលរដ្ឋទូទៅឲ្យរួចផុតពីបញ្ហាសព្វបែបយ៉ាង និងស្រោចស្រង់ជាតិតាមរយៈសកម្មភាពនយោបាយដោយដួងចិត្តសង្គ្រោះ ប្រាសចាកភាពអាត្មានិយមនោះទេ។

## ២. ការផ្លាស់ប្តូរផ្នត់គំនិតប្រជាពលរដ្ឋអំពីសីលធម៌សង្គម

អសីលធម៌សង្គម កង្វះក្រមសីលធម៌វិជ្ជាជីវៈ ការគិតតែប្រយោជន៍ផ្ទាល់ខ្លួន និងការអនុវត្តច្បាប់ធូរលុង កំពុងតែត្រូវបានប្រព្រឹត្តយ៉ាងរាលដាលនៅក្នុងប្រទេសដោយប្រជាពលរដ្ឋទូទៅតាមរយៈការបំពេញមុខងារវិជ្ជាជីវៈ ឬការប្រកបមុខរបររកស៊ី។ អ្នកលក់បន្លែផ្លែឈើ ត្រីសាច់ ចំណីអាហារ និងថ្នាំពេទ្យ បានឆ្លៀតប្រើប្រាស់សារធាតុគីមីដែលអាចជួយរក្សា ឬបង្កើនសោភណ័ភាពផលិតផលរបស់ខ្លួន តែវាបានបំផ្លាញសុខភាពប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់។ មន្ត្រីរាជការសាធារណៈឃុបឃិតគ្នាជាខ្សែសង្វាក់ដើម្បីកេងចំណេញប្រយោជន៍ផ្ទាល់ខ្លួន ឃ្លៃ ញធនធានធម្មជាតិ សម្បត្តិវប្បធម៌ខ្មែរ ធ្វើឲ្យបាត់បង់ចំណូលថវិការដ្ឋ និងជាងនេះទៀត អាជ្ញាធរគ្រប់លំដាប់ពុំបានចាត់វិធានការមានប្រសិទ្ធភាព

ដើម្បីទប់ស្កាត់ការហូរចូលខុសច្បាប់នៃនិគមន៍ជនបរទេស មកក្នុងប្រទេសនោះទេ។ អ្វីដែលធ្ងន់ធ្ងរជាងនេះទៀត ដោយសារកង្វះក្រមសីលធម៌វិជ្ជាជីវៈ មានបុគ្គលមួយក្រុមទៀតកំពុងតែបំផ្លាញការគិត និងបន្លំប្រជាពលរដ្ឋ ជាពិសេសពាក់ព័ន្ធទៅនឹងការបដិបត្តិសាសនា និងការវិភាគសេដ្ឋកិច្ចនយោបាយសង្គមរបស់គេ។ ក្រុមនេះកំពុងតែបំផ្លាញការគិត និងការយល់ដឹងរបស់ប្រជាពលរដ្ឋ។ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យចាត់ទុកការបំផ្លាញបែបនេះថាជាការបំផ្លាញខ្មែរដល់ឫសគល់តែម្តង។ ប្រជាពលរដ្ឋភាគច្រើនបាន និងកំពុងចូលរួមបំផ្លិចបំផ្លាញជាតិខ្មែរ និងពូជសាសន៍ខ្មែរម្នាក់បន្តិចៗ តាមគ្រប់រូបភាព និងស្ថានភាពរៀងៗខ្លួន ដោយដឹងខ្លួន ឬដោយមិនដឹងខ្លួនដែលត្រូវទៅនឹងការគ្រោងទុករបស់បរទេសដែលឈានដល់យុទ្ធសាស្ត្របច្ចុប្បន្នគឺ "ការដាក់ថ្នាំបន្ទន់ឆ្អឹង រួចលេបទាំងរស់"។

នៅពេលការអនុវត្តច្បាប់មានភាពធូររលុង និងគ្មានការដាក់ពិន័យឲ្យបានត្រឹមត្រូវ និងយុត្តិធម៌ចំពោះការរំលោភបំពានច្បាប់ ជាពិសេសដោយមន្ត្រីរាជការគ្រប់លំដាប់ និងគ្រប់វិស័យដូចបច្ចុប្បន្ននេះ ការពន្យល់ប្រជាពលរដ្ឋឲ្យស្គាល់ថាអ្វីជាអំពើល្អដែលខ្លួនគួរមានចំពោះខ្លួនឯង ចំពោះគ្រួសារ និងចំពោះសង្គមគឺជាការចាំបាច់ និងដើម្បីឲ្យពួកគាត់មានបុព្វហេតុច្បាស់លាស់ដើម្បីរស់នៅឲ្យបានជាប្រយោជន៍សម្រាប់ខ្លួនឯងផង និងសម្រាប់សង្គមផង។ ការពង្រឹងសីលធម៌ឲ្យប្រជាពលរដ្ឋខ្មែរម្នាក់ៗប្រកាន់ និងបដិបត្តិជាប់ជានិច្ចនូវធម៌ពីររបស់ព្រះសម្មាសម្ពុទ្ធ ៖ ការវៀរចាកនូវការប្រព្រឹត្តិអំពើអាក្រក់ និងការប្រព្រឹត្តិតែអំពើល្អ គឺជាធម៌យ៉ាងមានប្រសិទ្ធភាពសម្រាប់ការបំពេញការងារប្រកបដោយសីលធម៌វិជ្ជាជីវៈ និងការទទួលខុសត្រូវដោយខ្លួនឯង និងក៏ជាសម្ពាធយ៉ាងមានទម្ងន់

ធ្វើឲ្យអ្នកនយោបាយ និងអ្នកប្រវ័ញ្ចលាភក្នុងសាសនា លែងហ៊ានដើបមុខ ដោយចំហដើម្បីបោកប្រាស់ និងប្រព្រឹត្តអំពើអសីលធម៌នានាតទៅទៀត។

ដើម្បីឲ្យប្រជាពលរដ្ឋផ្លាស់ប្តូរផ្នត់គំនិតលើសីលធម៌សង្គម គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យបាន និងកំពុងពន្យល់ប្រជាពលរដ្ឋអំពី ៖

- តម្លៃពិតនៃជីវិត បុព្វហេតុនៃជីវិត និងការលះបង់ជីវិតដើម្បីបុព្វហេតុមាតុភូមិ និងពូជសាសន៍ខ្មែរដោយប្រាសចាកភាពអាត្មានិយម
- សារៈសំខាន់នៃសាមគ្គីភាពរវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋដោយឈរលើផលប្រយោជន៍រួម និងមនោសុចរិតនៃការជួយគ្នាទៅវិញទៅមកដើម្បីបង្កើតសង្គមដែលប្រជាពលរដ្ឋរស់នៅ ដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់
- កាតព្វកិច្ចរបស់ប្រជាពលរដ្ឋក្នុងភាពជាសមាជិកគ្រួសារ សហគមន៍ និងសង្គមដើម្បីឲ្យពួកគាត់ចូលរួមបង្កើតសង្គមប្រជាធិបតេយ្យ និងដេញកម្ចាត់ភាពអសកម្មរបស់ប្រជាពលរដ្ឋផ្សេងទៀត នៅក្នុងសង្គម
- ភាពខុសគ្នារវាងទង្វើបោកប្រាស់ និងទង្វើជួយសង្គ្រោះ ជាពិសេសទង្វើរបស់អ្នកនយោបាយ និងរបស់ធម្មកថិកដែលដេកត្រាំប្រវ័ញ្ចលាភក្នុងសាសនា
- ភាពខុសគ្នារវាងទង្វើអាក្រក់ និងទង្វើល្អ ទោះជាទង្វើតាមកាយ វាចា និងចិត្តរបស់ប្រជាពលរដ្ឋធម្មតា មន្ត្រីរាជការ ព្រះសង្ឃ អ្នកនយោបាយ អ្នកវិភាគនយោបាយសង្គមដោយឈរលើព្រះធម៌ជាគោល ហើយចូលរួមវាយកម្ចាត់អំពើអាក្រក់មិនដកដៃ

- សម្មាទិដ្ឋិដែលប្រជាពលរដ្ឋត្រូវប្រកាន់យកថា នយោបាយគឺជាកិច្ចការរបស់មនុស្សមានបេះដូងសុចរិត ហើយជួយសង្គ្រោះអ្នកដទៃដោយគ្មានភ្ជាប់ប្រយោជន៍ផ្ទាល់ខ្លួន
- តួនាទីមិនអាចខ្វះបានរបស់ប្រជាពលរដ្ឋម្នាក់ៗ ក្នុងការចូលរួមបង្កើត និងកសាងសង្គមប្រជាធិបតេយ្យឲ្យរីកចម្រើន និងថ្លៃថ្នូរដោយយកគំរូរបស់ប្រជាពលរដ្ឋនៅប្រទេសជឿនលឿន

*ការបកស្រាយលម្អិតនៃចំណុចនីមួយៗខាងលើនេះ មាននៅក្នុងសារសំឡេងដែលអាចរកបាននៅទីស្នាក់ការ ឬគេហទំព័រគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។*

## ៣. ការផ្លាស់ប្តូរផ្នត់គំនិតប្រជាពលរដ្ឋអំពីប្រជាធិបតេយ្យ/នយោបាយ

ប្រជាធិបតេយ្យគឺជាទម្រង់នៃការគ្រប់គ្រងរដ្ឋដែលសិទ្ធិ និងអំណាចក្នុងការចាត់ចែងកិច្ចការប្រទេសជាតិស្ថិតនៅក្នុងដៃរបស់ប្រជាពលរដ្ឋ ហើយការប្រើប្រាស់ប្រើសិទ្ធិ និងអំណាចជាម្ចាស់ត្រូវបានធានាជាអចិន្ត្រៃយ៍ដោយប្រព័ន្ធច្បាប់ដែលមានតុល្យភាពគ្នា (Checks-and-Balances System)។ ប្រវត្តិសាស្ត្រខ្មែរបង្ហាញយ៉ាងច្បាស់ពីមួយជំនាន់ទៅមួយជំនាន់ទៀតថា ដោយសារតែភាពល្ងង់ខ្លៅ និងការមិនយកចិត្តទុកដាក់លើកិច្ចការសង្គមរបស់ប្រជាពលរដ្ឋនេះហើយទើបអ្នកនយោបាយខ្មែរទុច្ចរិតអាចបោកប្រាស់ប្រជាពលរដ្ឋខ្លួនឯងឲ្យវង្វេង បាត់បង់ទ្រព្យសម្បត្តិ និងអាយុជីវិតជាច្រើនជំនាន់ដើម្បីឲ្យខ្លួនបានឡើងកាន់អំណាចក្រោមលេសអ្នកប្រជាធិបតេយ្យ និង/ឬអ្នកស្នេហាជាតិ។ ផលវិបាកនៃបទពិសោធចាញ់បោកអ្នកនយោបាយច្រើនជំនាន់ជាប់ៗគ្នា ធ្វើឲ្យប្រជាពលរដ្ឋយល់ឃើញថា ការធ្វើនយោបាយគឺជាមុខរបររកស៊ីមួយរបស់មនុស្សមួយក្រុម

ឬជាសកម្មភាពគ្រោះថ្នាក់ដែលខ្លួនមិនគួរប្រឡូកប្រឡាក់ជាមួយ។ ដើម្បីឲ្យប្រជាពលរដ្ឋមានសម្មាទិដ្ឋិចំពោះកិច្ចការនយោបាយ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យបាន និងកំពុងពន្យល់ប្រជាពលរដ្ឋឲ្យយល់ថា នយោបាយគឺជាកិច្ចការរបស់មនុស្សគ្រប់រូប ហើយជាកិច្ចការដែលខ្លួនត្រូវបំពេញជាប់ជាប្រចាំដោយការយល់ដឹងច្បាស់លាស់ក្នុងនាមជាប្រជាពលរដ្ឋម្ចាស់ប្រទេសដើម្បីជ្រើសរើសបានអ្នកនយោបាយដែលមានមនោសុចរិតជួយសង្គ្រោះនោះទើបប្រជាពលរដ្ឋអាចរួចផុតពីស្ថានភាពនៃការគ្រប់គ្រងប្រទេសដោយការប្រមូលផ្ដុំអំណាចដែលជាប្រភពនៃបញ្ហាស្រុកទេសសព្វបែបយ៉ាងតាំងតែពីដើមរៀងមក។

គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យយល់ឃើញយ៉ាងច្បាស់លាស់ថា លុះណាតែប្រជាពលរដ្ឋមានការយល់ត្រូវថា ខ្លួនត្រូវមានចំណេះដឹងច្បាស់លាស់អំពីប្រជាធិបតេយ្យ និងកាតព្វកិច្ចចូលរួមមិនអាចខ្វះបានរបស់ពួកគាត់ក្នុងការបង្កើតសង្គមប្រជាធិបតេយ្យ ឲ្យស្របតាមគតិបណ្ឌិតរបស់ប្រធានាធិបតីសហរដ្ឋអាមេរិក Abraham Lincoln (ប្រធានាធិបតីពីឆ្នាំ១៨៦១ដល់១៨៦៥)ដែលថា "រដ្ឋាភិបាលប្រជាធិបតេយ្យ គឺជារដ្ឋាភិបាលដែលបង្កើតឡើងដោយប្រជាពលរដ្ឋរបស់ប្រជាពលរដ្ឋ និងដើម្បីប្រជាពលរដ្ឋ" ទើបសង្គមប្រជាធិបតេយ្យអាចនឹងកើតឡើងនៅក្នុងមាតុភូមិរបស់យើង និងជាចលករសម្រាប់ជំរុញឲ្យមានការអភិវឌ្ឍប្រទេស តាមការចង់បានរបស់ប្រជាពលរដ្ឋភាគច្រើននៅក្នុងសង្គម។ គតិបណ្ឌិតនេះមានលក្ខខណ្ឌចំនួនបី (១)ដោយប្រជាពលរដ្ឋមានន័យថា ប្រជាពលរដ្ឋជាអ្នកជ្រើសរើសតំណាងរបស់ខ្លួននៅគ្រប់លំដាប់ (ភូមិ ឃុំ ស្រុក ខេត្ត និងជាតិ) ដោយចំពោះមុខ និងមានតម្លាភាព (២)របស់ប្រជាពលរដ្ឋមានន័យថា ប្រជាពលរដ្ឋជាអ្នកបោះឆ្នោតទម្លាក់តំណាងពីមុខតំណែងនោះវិញនៅពេលតំណាងនោះមិនធ្វើការឆ្លើយតបនឹងផលប្រយោជន៍ប្រជាពលរដ្ឋ នៅពេល

ណាក៏បាន លើកលែងតែតំណាងណាដែលត្រូវទម្លាក់នៅពេលដាច់អាណត្តិដែលកំណត់ដោយច្បាប់ និង(៣)ដើម្បីប្រជាពលរដ្ឋមានន័យថា តំណាងត្រូវតែបំពេញការងារដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋដែលតម្រូវដោយប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋដែលមានតុល្យភាពអំណាចរវាងអំណាចរដ្ឋាភិបាល និងអំណាចប្រជាពលរដ្ឋ។

ដើម្បីឲ្យប្រជាពលរដ្ឋផ្លាស់ប្តូរផ្នត់គំនិតអំពីប្រជាធិបតេយ្យ/នយោបាយគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យបាន និងកំពុងពន្យល់ប្រជាពលរដ្ឋអំពី ៖

- តួនាទីដ៏សំខាន់ទូលំទូលាយ និងមានប្រសិទ្ធភាពរបស់អ្នកនយោបាយសុចរិតដើម្បីដោះស្រាយបញ្ហាស្រុកទេសសព្វបែបយ៉ាងរបស់ប្រជាពលរដ្ឋ ខ្មែរជាទូទៅដូចបានរៀបរាប់នៅក្នុងបុព្វកថានៃឯកសារនេះ
- លក្ខណៈខុសគ្នាជាសារវន្តនៃប្រព័ន្ធដឹកនាំរដ្ឋ ដែលប្រមូលផ្តុំអំណាចនាពេលបច្ចុប្បន្ន និងប្រសិទ្ធភាពនៃប្រព័ន្ធដឹកនាំរដ្ឋដោយប្រព័ន្ធដែលពង្រាយអំណាចនាពេលអនាគត
- សង្គមប្រជាធិបតេយ្យ របៀបបង្កើតសង្គមប្រជាធិបតេយ្យ និងផលប្រយោជន៍ដែលកើតមានពីសង្គមប្រជាធិបតេយ្យ
- សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងភាពជាម្ចាស់ប្រទេស ករណីយកិច្ចមិនអាចខ្វះបានក្នុងភាពជាម្ចាស់ក្នុងការចូលរួមអភិវឌ្ឍប្រទេស និងអំណាចដែលប្រជាពលរដ្ឋត្រូវមានជាអចិន្ត្រៃយ៍ដើម្បីអនុវត្តសិទ្ធិជាម្ចាស់ឲ្យមានប្រសិទ្ធភាព

- គោលដៅ បំណុ ចចាប់ផ្ដើម ឥរិយាបថនយោបាយ និងធនធានមនុស្ស នៃចលនានយោបាយរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យដើម្បី បង្កើតសង្គមប្រជាធិបតេយ្យនៅដំណាក់កាលដំបូង និងប្រែក្លាយ កម្ពុជាឲ្យទៅជាមាតុភូមិមួយ ដែលពួកយើងរស់នៅដោយស្មើភាពគ្នា ក្នុងភាពជាម្ចាស់នៅដំណាក់កាលបន្ទាប់

- ភាពមិនអាចខ្វះបាននៃការចូលរួមរបស់ប្រជាពលរដ្ឋ ជាមួយគណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យដើម្បីបញ្ចប់ការធ្វើនយោបាយ ដោយការដើរ តាម ដោយការស្រលាញ់ និងដោយការដឹងគុណមកជាការធ្វើនយោបាយ ដោយការរួមគិត រួមធ្វើ រួមទទួលខុសត្រូវ ស្របតាមបាវចនារបស់ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ

- បំណុ ចខ្លាំង និងចំណុចខ្សោយរបស់គណបក្សនយោបាយនានានៅ កម្ពុជា ជាពិសេសពាក់ព័ន្ធទៅនឹងទស្សនវិស័យ ឥរិយាបថនយោបាយ និងធនធានមនុស្ស សម្រាប់ចលនានយោបាយរបស់គណបក្សនីមួយៗ

- ចំណេះដឹងចាំបាច់ និងវិធីសាស្ត្រមានប្រសិទ្ធភាពសម្រាប់តាមដាន និង បញ្ចប់ជីវិតនយោបាយ ដែលមានលក្ខណៈបោកប្រាស់ដែលចេះតែ សន្យាផ្ដេស ផ្ដាស នៅចំពោះមុខប្រជាពលរដ្ឋដើម្បីឲ្យតែបានសន្លឹក ឆ្នោត និងលាភសក្ការៈពីសកម្មភាពនយោបាយ គ្មានគោលដៅច្បាស់ លាស់ដោយមិនគិតពីឥទ្ធិពលអវិជ្ជមានជះចូលទៅក្នុងសង្គម

- វិធានការច្បាស់លាស់ដែលអាចអនុវត្តបាន និងមានផលប្រយោជន៍ យូរអង្វែងដើម្បីបំបែកប្រពន្ធដឹកនាំដែលប្រមូលផ្ដុំអំណាច និងដោះ ស្រាយបញ្ហាស្រុកទេសសព្វបែបយ៉ាងប្រកបដោយប្រសិទ្ធភាពគឺ

"យន្តការប្រាំបីចំណុច" ដែលមានការបកស្រាយខ្លឹមសារលម្អិតនៅផ្នែកខាងក្រោម

*ការបកស្រាយលម្អិតនៃចំណុចនីមួយៗខាងលើនេះមាននៅក្នុងសារសំឡេងដែលអាចរកបាននៅទីស្នាក់ការគណបក្ស ឬគេហទំព័រគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។*

ប្រជាធិបតេយ្យគឺជាទម្រង់នៃការគ្រប់គ្រងរដ្ឋមួយដ៏មានសក្តានុពលសម្រាប់ឲ្យប្រជាពលរដ្ឋទទួលផលដោយស្មើភាពគ្នា (មិនមែនស្មើគ្នាទេ) ពីការអភិវឌ្ឍប្រទេសជាតិ។ ដើម្បីទាញយកប្រយោជន៍ពីប្រជាធិបតេយ្យ ប្រជាពលរដ្ឋត្រូវតែផ្លាស់ប្តូរផ្នត់គំនិតរបស់ខ្លួនពីការទន្ទឹងរង់ចាំប្រជាធិបតេយ្យ ពីសំណាក់មេដឹកនាំធ្វើឲ្យ មកជាការចូលរួមយ៉ាងសកម្ម ជាប្រចាំដោយការយល់ដឹងច្បាស់លាស់ និងការទទួលខុសត្រូវក្នុងសកម្មភាពនយោបាយរបស់ប្រទេសជាតិ ជាពិសេសការចូលរួមនៅដំណាក់កាលនេះដើម្បីបំបែកប្រព័ន្ធដឹកនាំដែលប្រមូលផ្តុំអំណាចតាមរយៈការដាក់ឲ្យអនុវត្តច្បាប់ ដែលកើតចេញពីយន្តការប្រាំបីចំណុច ចជាមួយគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។

គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យយល់ឃើញថា ប្រសិនបើផ្នត់គំនិតរបស់ប្រជាពលរដ្ឋលើគោលធំៗទាំងបីខាងលើមិនទាន់ត្រូវបានផ្លាស់ប្តូរទេ បើទោះបីជាគណបក្សសម្ព័ន្ធ ដើម្បីប្រជាធិបតេយ្យឈ្នះឆ្នោតដើម្បីដឹកនាំស្រុកទេសក៏ដោយ ក៏គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យមិនអាចនាំប្រជាពលរដ្ឋទៅដល់គោលដៅនៃការប្រែក្លាយ "កម្ពុជាឲ្យទៅជាមាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពក្នុងភាពជាម្ចាស់" បានដែរ។ ការផ្លាស់ប្តូរផ្នត់គំនិតរបស់

ប្រជាពលរដ្ឋគឺជាកត្តាគន្លឹះដែលគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យត្រូវតែសម្រេចឲ្យបាននៅដំណាក់កាលដំបូង មុននឹងខ្លួនឈានទៅសម្រេចគោលដៅនៃការប្រែក្លាយយន្តការប្រាំបីចំណុ ចឲ្យទៅជាច្បាប់នៅដំណាក់កាលបន្ទាប់។

ចំនួនប្រជាពលរដ្ឋដែលបានផ្លាស់ប្តូរផ្នត់គំនិតលើគោលធំៗទាំងបី របស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ជាពិសេសលើកិច្ចបដិបត្តិព្រះធម៌ និងសីលធម៌សង្គមកាន់តែមានចំនួនច្រើនឡើងចាប់តាំងពីគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ចាប់ផ្តើមផ្សព្វផ្សាយសកម្មភាពរបស់ខ្លួនអស់រយៈពេលជាង៦ឆ្នាំ ដោយគិតពីថ្ងៃបង្កើតគណបក្សនៅឆ្នាំ២០០៦ ទោះបីជាការផ្សព្វផ្សាយនេះមិនទាន់មានច្រើនទម្រង់ និងបានទូលំទូលាយឲ្យដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេសនៅឡើយក៏ដោយ។

ប្រជាពលរដ្ឋមានចំនួនកាន់តែច្រើនឡើង ដែលបានតាមដានសកម្មភាពរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានយល់ដឹង និងបានផ្លាស់ប្តូរផ្នត់គំនិតជាបណ្តើរៗ ទាំងទម្រង់នៃការធ្វើនយោបាយ ទាំងការរស់នៅ និងទាំងការបដិបត្តិព្រះធម៌។ មានគ្រួសារជាច្រើនដែលបានប្រែក្លាយទៅជាគ្រួសាររស់នៅសុខសាន្តក្នុងទំនាក់ទំនងរវាងប្តីប្រពន្ធ ឪពុកម្តាយ និងកូន ក្រោយពេលមានការយល់ដឹងអំពីសីលធម៌បុគ្គល សីលធម៌គ្រួសារ សីលធម៌សង្គម និងព្រះធម៌ត្រង់ផ្នែកដែលពាក់ព័ន្ធនឹងជីវិតដែលបានពន្យល់ ដោយគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។ មានគ្រួសារយល់ដឹងខ្លះបានសន្សំថវិកាបានមួយចំនួនដោយរួចផុតពីការបោកប្រាស់ក្នុងវិស័យសាសនា ដោយព្រះសង្ឃ និងធម្មាចារ្យទុច្ចរិតមួយចំនួន ដូចជារួចពីការធ្វើបុណ្យខ្ជះ ខ្ជាយដោយខ្វះការយល់ដឹង។ នេះគឺជាលទ្ធផលជាក់ស្តែងរបស់ប្រជាពលរដ្ឋ ដែលកើតចេញពីការពន្យល់របស់គណបក្សសម្ព័ន្ធ

ដើម្បីប្រជាធិបតេយ្យដើម្បីឲ្យប្រជាពលរដ្ឋមានការផ្លាស់ប្តូរផ្នត់គំនិតសម្រាប់ការរស់នៅ និងការបដិបត្តិព្រះធម៌។

ដោយផ្តើមចេញពីការយល់ដឹង និងការផ្លាស់ប្តូរផ្នត់គំនិតនេះហើយ ទើបប្រជាពលរដ្ឋគ្រប់និន្នាការនយោបាយគ្រប់ទីកន្លែង និងជាពិសេសប្រជាពលរដ្ឋក្មេងៗបានចូលរួមជាមួយគណបក្សសម្ព័ន្ធ ដើម្បីប្រជាធិបតេយ្យយ៉ាងសកម្ម។ នេះគឺជាការចូលរួមដោយទឹកចិត្តបរិសុទ្ធ គ្មានចង់បានអ្វី ជាប្រយោជន៍ផ្ទាល់ខ្លួនត្រលប់មកវិញ។ ជាទូទៅ ការចូលរួមមានបីទម្រង់ គឺការចូលរួមជាកម្លាំងកាយ ការចូលរួមថវិកា និងការចូលរួមចំណេះដឹង។ ដោយសារការចូលរួមទាំងនេះ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យអាចដំណើរការសកម្មភាពរបស់ខ្លួនបានរហូតមកដល់ពេលបច្ចុប្បន្ននេះ។ សន្ទុះនៃការគាំទ្រនេះចេះតែបន្តកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ទាំងចំនួនអ្នកចូលថវិកា ទាំងចំនួនអ្នកចូលរួមធ្វើជាវាគ្មិនក្នុងវេទិកា និងការផ្សាយផ្ទាល់តាមវិទ្យុ។ ទម្រង់មួយទៀតនៃការចូលរួមផ្សព្វផ្សាយទស្សនៈ គឺមានអ្នកគាំទ្រគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យមួយចំនួនបានរៀបចំការផ្សព្វផ្សាយរបស់ខ្លួនឲ្យទៅជាទម្រង់បោះពុម្ពលើក្រដាស និងតាមបណ្តាញសង្គមនានា ដូចជាគេហទំព័រ ហ្វេសប៊ុក Youtube និង Paltalk ដើម្បីពង្រីកការផ្សព្វផ្សាយរបស់ខ្លួនឲ្យបានទៅដល់ប្រជាពលរដ្ឋឲ្យកាន់តែទូលំទូលាយ និងដើម្បីចងក្រងឯកសារសម្រាប់ការស្រាវជ្រាវ និងទុកជាមរតកសម្រាប់អ្នកនយោបាយជំនាន់ក្រោយៗទៀតធ្វើបន្ត។

គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យគឺជាគណបក្សនយោបាយដែលបានផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋ ជាពិសេសបានផ្តល់ចំណេះដឹងដែលពាក់ព័ន្ធ

នឹងគោលធំៗបី ៖ ប្រជាធិបតេយ្យ/នយោបាយ កិច្ចបដិបត្តិព្រះធម៌ និង សីលធម៌សង្គម ទោះបីជាមិនទាន់បានទទួលអាសនៈតំណាងរាស្ត្រនៅឡើយក្តី។ ការពង្រឹងចំណេះដឹង និងមូលដ្ឋានសម្រាប់ពិចារណាជូនប្រជាពលរដ្ឋលើគោលធំៗទាំងបីនេះ បានធ្វើឲ្យគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យទទួលបានការគាំទ្រកាន់តែច្រើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។

ការពន្យល់អំពីយន្តការបង្កើតសង្គមប្រជាធិបតេយ្យ

ផ្នែកនេះនិយាយអំពីចំណុចសំខាន់នៃនិយមន័យប្រជាធិបតេយ្យ យន្តការប្រាំបីចំណុច និងកាតព្វកិច្ចនៃការចូលរួមរបស់ប្រជាពលរដ្ឋដើម្បីប្រែក្លាយសង្គមកម្ពុជាទៅជាសង្គមប្រជាធិបតេយ្យ។

ប្រជាធិបតេយ្យគឺជាទម្រង់នៃការគ្រប់គ្រងរដ្ឋដែលសិទ្ធិ និងអំណាចក្នុងការចាត់ចែងកិច្ចការប្រទេសជាតិស្ថិតនៅក្នុងដៃរបស់ប្រជាពលរដ្ឋដែលការប្រើប្រាស់សិទ្ធិ និងអំណាចជាម្ចាស់ ត្រូវបានធានាជាអចិន្ត្រៃយ៍ដោយប្រព័ន្ធច្បាប់ដែលមានតុល្យភាព។ នៅក្នុងប្រព័ន្ធច្បាប់ដែលមានតុល្យភាព ប្រជាពលរដ្ឋជាអ្នកមានសិទ្ធិ និងអំណាចក្នុងការជ្រើសរើសអ្នកដឹកនាំឲ្យទៅកាន់កិច្ចការស្រុកទេសផង និងដើម្បីដាក់អ្នកដឹកនាំឲ្យទទួលខុសត្រូវចំពោះកម្មវិធីនយោបាយ និងទង្វើរបស់ខ្លួននៅពេលកំពុងកាន់មុខតំណែងផង។ ប្រជាពលរដ្ឋជាអ្នកជ្រើសរើសតំណាងថ្នាក់ជាតិ (សភា និងព្រឹទ្ធសភា) និងតំណាងថ្នាក់ក្រោមជាតិ (ចៅហ្វាយខេត្ត ចៅហ្វាយស្រុក មេឃុំ មេភូមិ និងក្នុងស្ថាប័នផ្សេងៗទៀត) តាមរយៈការបោះឆ្នោតដោយផ្ទាល់ ដោយសេរី ដោយយុត្តិធម៌ និងដោយទៀងទាត់។ ប្រធានាធិបតីសហរដ្ឋអាមេរិក អាប្រាហាម លីនកូល (Abraham Lincoln) មានប្រសាសន៍ថា "រដ្ឋាភិបាលប្រជាធិបតេយ្យគឺជារដ្ឋាភិបាលដែលបង្កើតឡើងដោយប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ និងដើម្បីប្រជាពលរដ្ឋ"។ ប្រទេសនីមួយៗ

កំណត់និយមន័យ និងប្រើប្រាស់វិធីសាស្ត្រខុសៗគ្នាដើម្បីបង្កើតសង្គមប្រជាធិបតេយ្យ ដែលសមស្របតាមបរិបទរបស់ប្រទេសរៀងៗខ្លួន។ ពុំមានវិធីសាស្ត្រជាក់លាក់ណាមួយត្រូវបានគេយកទៅអនុវត្តជាទូទៅ ដើម្បីបង្កើតសង្គមប្រជាធិបតេយ្យនោះទេ។

ខាងក្រោមនេះគឺជាយន្តការ ដែលគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យយល់ឃើញថាសមស្របសម្រាប់កាលៈទេសៈបច្ចុប្បន្ននៅកម្ពុជាសម្រាប់អនុវត្តដើម្បីប្រែក្លាយសង្គមកម្ពុជាឲ្យទៅជាសង្គមប្រជាធិបតេយ្យ។

## យន្តការប្រាំបីចំណុច

ដោយគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យយល់ឃើញថា ការដឹកនាំដោយប្រព័ន្ធដែលប្រមូលផ្តុំអំណាចជាប្រភពនៃបញ្ហាស្រុកទេសសព្វបែបយ៉ាង ទើបគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យចាត់ទុកយន្តការប្រាំបីចំណុចជាវិធានការផ្លូវច្បាប់មានប្រសិទ្ធភាព បន្ថែមលើវិធានការសីលធម៌តាមរយៈការផ្លាស់ប្តូរផ្នត់គំនិតលើគោលធំៗទាំងបីសម្រាប់បំបែកប្រព័ន្ធ ដែលប្រមូលផ្តុំអំណាចមកជាប្រព័ន្ធដែលពង្រាយអំណាច។

### ១. កំណត់អាណត្តិនាយករដ្ឋមន្ត្រីត្រឹមពីរអាណត្តិ

មាត្រា១នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា ប្រទេសកម្ពុជាជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ គណបក្សនយោបាយណាដែលទទួលបានអាសនៈរដ្ឋសភាពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រច្រើនជាងគេគឺជាគណបក្សដែលស្នើបេក្ខភាព

នាយករដ្ឋមន្ត្រីដែលគណបក្សបានសម្រេចជ្រើសរើសពីក្នុងគណបក្ស មុនការបោះឆ្នោតដើម្បីឲ្យរដ្ឋសភាបោះឆ្នោតគាំទ្រឲ្យបេក្ខជននោះក្លាយជានាយករដ្ឋមន្ត្រីដើម្បីដឹកនាំរដ្ឋាភិបាលក្នុងអាណត្តិប្រាំឆ្នាំរបស់ខ្លួន។ រដ្ឋធម្មនុញ្ញមិនបានកំណត់ថា បុគ្គលម្នាក់អាចធ្វើនាយករដ្ឋមន្ត្រីបានប៉ុន្មានអាណត្តិនោះទេ ពោលគឺបុគ្គលម្នាក់អាចធ្វើជានាយករដ្ឋមន្ត្រីច្រើនអាណត្តិ ដរាបណាគណបក្សរបស់បុគ្គលនោះឈ្នះក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងបុគ្គលនោះបានទទួលការគាំទ្រពីរដ្ឋសភា។

នាយករដ្ឋមន្ត្រីគឺជាបុគ្គលដែលមានឥទ្ធិពលយ៉ាងខ្លាំងក្នុងគណបក្ស និងមានអំណាចខ្ពស់ជាងគេបំផុតនៅក្នុងអំណាចនីតិប្រតិបត្តិ។ លើសពីនេះទៀត ដោយហេតុថា ប្រទេសកម្ពុជាកំពុងតែគ្រប់គ្រងដោយប្រព័ន្ធដែលប្រមូលផ្តុំអំណាច នាយករដ្ឋមន្ត្រីអាចប្រើប្រាស់ឥទ្ធិពលដើម្បីគ្របដណ្តប់ទៅលើអំណាចពីរទៀត ៖ អំណាចនីតិប្បញ្ញត្តិ និងអំណាចតុលាការ។ ដោយសារតែនាយករដ្ឋមន្ត្រីមានអំណាចលើស្ថាប័ន ទាំងបីយ៉ាងដូច្នេះ ទើបនាយករដ្ឋមន្ត្រីអាចលូកដៃចូលក្នុងស្ថាប័នរដ្ឋ និងឯកជនគ្រប់លំដាប់ទាំងអស់។ ជាផលវិបាកនៃការគ្រប់គ្រងបែបប្រព័ន្ធដែលប្រមូលផ្តុំអំណាចនេះ ទាំងមន្ត្រីរាជការជំតូច ទាំងប្រជាពលរដ្ឋមិនថាអ្នកមាន ឬអ្នកក្រនោះទេ តែងរុញការទទួលខុសត្រូវទាំងអស់ ដែលទាក់ទងនឹងប្រទេសជាតិទៅឲ្យនាយករដ្ឋមន្ត្រីទទួលខុសត្រូវតែម្នាក់ឯង។ ដោយមានការទទួលខុសត្រូវយ៉ាងធំធេងយ៉ាងដូច្នេះ នាយករដ្ឋមន្ត្រីត្រូវតែបង្កើតបណ្តាញបក្ខពួករបស់ខ្លួនតាមគ្រប់រូបភាពទាំងអស់ដើម្បីឲ្យប្រព័ន្ធ ដែលប្រមូលផ្តុំអំណាចអាចបន្តនិរន្តរភាពបាន។

គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យយល់ឃើញថា ការកាន់កាប់មុខតំណែងជានាយករដ្ឋមន្ត្រីច្រើនអាណត្តិនៅក្នុងប្រទេសដែលកំពុងមានបញ្ហា ដូចជាប្រទេសកម្ពុជា នាំឲ្យមានគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋផង និងប្រទេសជាតិផង។ នៅពេលដែលបុគ្គលណាម្នាក់កាន់មុខតំណែងជានាយករដ្ឋមន្ត្រីច្រើនឆ្នាំ បុគ្គលនោះអាចបង្កើតបណ្ដាញគ្រប់គ្រងរបស់ខ្លួននៅគ្រប់លំដាប់ទាំងក្នុងកិច្ចការរដ្ឋ និងក្នុងកិច្ចការពាណិជ្ជកម្ម។ នៅពេលនោះ កិច្ចការគ្រប់គ្រងស្រុកទេសហាក់បីដូចជាការគ្រប់គ្រងគ្រួសារ ដែលរាល់ការសម្រេចទាំងអស់នៅលើតែបុគ្គលជាមេគ្រួសារដែលពុំមានការអនុវត្តច្បាប់ ឲ្យមានប្រសិទ្ធភាពចំពោះពលរដ្ឋទូទៅទេ។ ការគ្រប់គ្រងបែបនេះធ្វើឲ្យបុគ្គលដែលមានអំណាច និងទ្រព្យសម្បត្តិអាចប្រព្រឹត្តអំពើទាំងឡាយតាមតែអំពើចិត្តរបស់ខ្លួនដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួន គ្រួសារខ្លួន និងបក្ខពួកខ្លួន។

លើសពីនេះទៀត ការកាន់មុខតំណែងជានាយករដ្ឋមន្ត្រីយូរឆ្នាំរបស់បុគ្គលតែមួយរូបបានជំរុញឲ្យមន្ត្រីរាជការគ្រប់លំដាប់របស់រដ្ឋ ក្លាយជាឧបករណ៍នយោបាយរបស់គណបក្សកាន់អំណាចនោះ ហើយពួកគាត់រុញការទទួលខុសត្រូវទៅឲ្យថ្នាក់លើរបស់ខ្លួនដើម្បីបង្ហាញប្រជាពលរដ្ឋថា ខ្លួនពុំមែនជាអ្នកខុសនោះទេ នៅពេលដែលខ្លួនបំពេញភារកិច្ចរបស់ខ្លួនមិនបានជោគជ័យ។ ស្ថិតនៅក្នុងស្ថានភាពបែបនេះ បើទោះជានាយករដ្ឋមន្ត្រីនោះមានបេះដូងបរិសុទ្ធចង់បម្រើប្រជាពលរដ្ឋទូទាំងប្រទេសក៏ដោយ ក៏គាត់មិនអាចធ្វើបាន ដោយមានប្រសិទ្ធភាពនោះដែរ។ ពីមួយឆ្នាំទៅមួយ ឆ្នាំនៃការកាន់មុខតំណែងនាយករដ្ឋមន្ត្រី នាយករដ្ឋមន្ត្រីរូបនោះកាន់តែបង្កអវិភាពច្រើនឡើងៗ ជាមួយនឹងបុគ្គលទាំងឡាយនៅជុំវិញខ្លួន មិនថាជាបុគ្គលសាមញ្ញ ឬបុគ្គលមានមុខតំណែងធំដុំ ដោយសារ

តែទំនាស់ផលប្រយោជន៍ និងវិជ្ជាជីវៈ។ លទ្ធផលចុងក្រោយនៃការគ្រប់គ្រងប្រទេសបែបនេះគឺថា ប្រជាពលរដ្ឋម្នាក់ៗ ទោះបីក្នុងសមាសភាពគាត់ជារដ្ឋមន្ត្រី ឬកសិករនៅតំបន់ដាច់ស្រយាលយ៉ាងណា គឺពួកគាត់នឹងទម្លាក់ការទទួលខុសត្រូវទាំងអស់ដល់នាយករដ្ឋមន្ត្រី ហើយធ្វើឲ្យនាយករដ្ឋមន្ត្រីអាចនឹងរងការចោទប្រកាន់ផ្សេងៗ នៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួនផងក៏ថាបាន។

ការកំណត់អាណត្តិនាយករដ្ឋមន្ត្រីត្រឹមពីរអាណត្តិគឺជាការចាំបាច់ដើម្បីជៀសវាងកុំឲ្យបុគ្គលណាម្នាក់ ដែលជានាយករដ្ឋមន្ត្រីមានឱកាសបង្កើតបណ្ដាញខ្សែរយៈគ្រួសារ និងបក្ខពួកក្នុងស្ថាប័នរដ្ឋដែលជាប្រព័ន្ធពង្រឹងអំណាចបុគ្គលដែលអាចនាំឲ្យមានការបង្កើតរបបផ្ដាច់ការ បក្ខពួក ឬក្រុមគ្រួសារនិយម និងការបំផ្លិ ញផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋ។ បន្ថែមពីលើនេះទៀត ការកំណត់អាណត្តិនាយករដ្ឋមន្ត្រីត្រឹមពីរអាណត្តិ គឺជាការរំដោះនាយករដ្ឋមន្ត្រីឲ្យរួចផុតពីការទទួលខុសត្រូវគ្រប់បញ្ហាតែម្នាក់ឯងផង និងជាការផ្ដល់ឱកាសឲ្យអ្នកផ្សេងៗទៀតអាចអភិវឌ្ឍប្រទេស តាមទិសដៅផ្សេងៗពីនាយករដ្ឋមន្ត្រីមុនផង។ លទ្ធផលមួយនៃលទ្ធផលជាច្រើន ដែលនឹងកើតចេញពីការកំណត់អាណត្តិនាយករដ្ឋមន្ត្រីត្រឹមពីរអាណត្តិគឺថា ប្រជាពលរដ្ឋម្នាក់ៗ ត្រូវតែទទួលខុសត្រូវចំពោះជោគវាសនារបស់ប្រទេសជាតិ ក្នុងកម្រិតស្មើៗគ្នា ដូចនាយករដ្ឋមន្ត្រីយ៉ាងដូច្នេះដែរនៅក្នុងតួនាទីរបស់ខ្លួនម្នាក់ៗ ហើយវប្បធម៌នៃការមិនទទួលខុសត្រូវរបស់មន្ត្រីសាធារណៈចំពោះភារកិច្ចរបស់ខ្លួននឹងត្រូវបញ្ចប់។

*នៅពេលយន្តការនេះត្រូវបានប្រែក្លាយជាច្បាប់សម្រាប់អនុវត្ត បុគ្គលម្នាក់អាចធ្វើជានាយករដ្ឋមន្ត្រីបានត្រឹម១០ឆ្នាំប៉ុណ្ណោះយ៉ាងយូរបំផុត ដូច្នេះ បុគ្គលនោះនឹងមិនមានឱកាសដើម្បីបង្កើតបណ្ដាញបក្ខពួករបស់ខ្លួននៅក្នុងប្រទេស និង*

*មានឥទ្ធិពលទៅលើអំណាចផ្សេងទៀតរបស់រដ្ឋ ពោលគឺអំណាចនីតិប្បញ្ញត្តិ និងអំណាចតុលាការឡើយ។ ម៉្យាងវិញទៀត បុគ្គលដែលនឹងត្រូវធ្វើជានាយករដ្ឋមន្ត្រីបន្ទាប់អាចនាំមកនូវទស្សនវិស័យផ្សេងៗគ្នាសម្រាប់ការអភិវឌ្ឍជាតិបន្ត។*

## ២. មិនអនុញ្ញាតឲ្យនាយករដ្ឋមន្ត្រីបង្កើតក្រុមអង្គរក្សដោយខ្លួនឯង

ទោះបីជាការកំណត់អាណត្តិនាយករដ្ឋមន្ត្រីត្រឹមពីរអាណត្តិគឺជាវិធានការទប់ស្កាត់នាយករដ្ឋមន្ត្រីមិនឲ្យបង្កើតបណ្តាញបក្ខពួកគ្រប់គ្រងប្រទេសក៏ដោយ ក៏នាយករដ្ឋមន្ត្រីនៅតែអាចបំពេញការងារដើម្បីក្រុមគ្រួសារខ្លួន ឬបក្ខពួកខ្លួនក្នុងរយៈពេលពីរអាណត្តិនេះដែរ ប្រសិនបើនាយករដ្ឋមន្ត្រីនោះមានអំណាចពោរពាសដោយសារតែខ្លួនមានកម្លាំងប្រដាប់អាវុធតាមរយៈកងអង្គរក្សរបស់ខ្លួន។ ដូច្នេះដើម្បីកុំឲ្យនាយករដ្ឋមន្ត្រីអាងកម្លាំងអង្គរក្សរបស់ខ្លួនទៅបង្ក្រាបអ្នកណាដែលមិនយល់ស្របតាមសេចក្តីសម្រេចក្រៅផ្លូវច្បាប់របស់គាត់ នាយករដ្ឋមន្ត្រីមិនត្រូវអនុញ្ញាតឲ្យបង្កើតកងអង្គរក្សដោយខ្លួនឯងនោះទេ។

សុវត្ថិភាពនាយករដ្ឋមន្ត្រីដែលជាថ្នាក់ដឹកនាំកំពូលរបស់ជាតិ គឺជាក្តីបារម្ភរបស់ប្រជាពលរដ្ឋគ្រប់រូប។ ដូច្នេះ នាយករដ្ឋមន្ត្រីត្រូវតែមានអង្គរក្សការពារគាត់ឲ្យមានសុវត្ថិភាពខ្ពស់បំផុត មិនថានាយករដ្ឋមន្ត្រីនៅទីណានោះទេ។ ប៉ុន្តែ កងអង្គរក្សមិនត្រូវបង្កើតឡើងដោយនាយករដ្ឋមន្ត្រីខ្លួនឯងឡើយ។ មេកងអង្គរក្សអាចត្រូវស្នើឡើងដោយនាយករដ្ឋមន្ត្រី ដើម្បីឲ្យសភាអនុម័តផ្តល់សេចក្តីទុកចិត្ត។ ដូច្នេះ ក្រុមអង្គរក្សនឹងមិនទទួលរងសម្ពាធពីនាយករដ្ឋមន្ត្រី ហើយពួកគាត់ដឹងយ៉ាងច្បាស់ថា ខ្លួនគឺជាមន្ត្រីរាជការដែលទទួលការចាត់តាំងឲ្យទៅការ

ពារនាយកដ្ឋមន្ត្រី ដូចមន្ត្រីរាជការដទៃទៀត ដែលត្រូវបំពេញការងារវិជ្ជាជីវៈរបស់ខ្លួនតែរៀងៗខ្លួនយ៉ាងដូច្នោះដែរ។

ក្នុងឋានៈបែបនេះ កងអង្គរក្សអាចបំពេញការងាររបស់ខ្លួនដោយឯករាជ្យ និងមានវិជ្ជាជីវៈខ្ពស់ មានការទទួលខុសត្រូវ ទាំងការការពារនាយករដ្ឋមន្ត្រីដើម្បីឲ្យនាយករដ្ឋមន្ត្រីអាចធ្វើដំណើរ និងបំពេញការងារឲ្យជាតិមាតុភូមិដោយសុវត្ថិភាព ហើយកងអង្គរក្សដដែលនេះក៏នឹងត្រូវបំពេញការងារដោយសហការជាមួយស្ថាប័នតុលាការដើម្បីចាប់ខ្លួននាយករដ្ឋមន្ត្រីផងដែរ បើកាលៈទេសៈតម្រូវឲ្យធ្វើយ៉ាងដូច្នេះ។

*នៅពេលយន្តការនេះត្រូវបានប្រែក្លាយឲ្យទៅជាច្បាប់ នាយករដ្ឋមន្ត្រីនឹងមិនមានសិទ្ធិអំណាចជ្រើសរើសកងអង្គរក្ស ដើម្បីការពារខ្លួនឲ្យហួសពីតម្រូវការទៀតឡើយ។ អំណាចខាងកងកម្លាំងប្រដាប់អាវុធរបស់នាយករដ្ឋមន្ត្រីតាមរយៈកងអង្គរក្សក៏លែងមានទៀតដែរ។*

## ៣. តម្រូវឲ្យនាយករដ្ឋមន្ត្រីរស់នៅក្នុងនិវេសនដ្ឋានរដ្ឋ

បើទោះបីជាមានការកំណត់អាណត្តិនាយករដ្ឋមន្ត្រី និងការឲ្យនាយករដ្ឋមន្ត្រីទទួលបានការការពារតាមផ្លូវច្បាប់ដោយកងអង្គរក្សរដ្ឋហើយក៏ដោយ ក៏នាយករដ្ឋមន្ត្រីនៅតែអាចកៀងគរកម្លាំងសម្ងាត់នៅក្នុងគេហដ្ឋានរបស់គាត់ដើម្បីពង្រីកអំណាចរបស់គាត់ដោយមធ្យោបាយណាមួយផ្សេងទៀតក៏បាន។ គេអាចនិយាយម៉្យាងទៀតថា ការកំណត់ឲ្យនាយករដ្ឋមន្ត្រីរស់នៅក្នុងនិវេសនដ្ឋានរដ្ឋ ជាវិធានការបន្ថែមដើម្បីទប់ស្កាត់នាយករដ្ឋមន្ត្រីកុំឲ្យគាត់អាចរៀបចំ

គេហដ្ឋានរបស់គាត់ឲ្យទៅជាមានទ្រង់ទ្រាយ ដូចជាបន្ទាយទាហានផ្ទាល់ខ្លួនដើម្បីតែការពារគាត់ និងក្រុមគ្រួសារគាត់។

ការកំណត់ឲ្យនាយករដ្ឋមន្ត្រីរស់នៅក្នុងនិវេសនដ្ឋានរដ្ឋក៏មានគោលបំណងដើម្បីឲ្យបុគ្គលណាម្នាក់ នៅពេលធ្វើជានាយករដ្ឋមន្ត្រីរស់នៅដោយតម្លាភាព និងផាសុកភាព ទាំងក្នុងពេលបំពេញការងារ និងជីវិតឯកជន។ ការរស់នៅក្នុងនិវេសនដ្ឋានរដ្ឋគឺជាវិធានការចាំបាច់ដើម្បីការពារសន្តិសុខ និងទំនុកបម្រុងជីវភាពរស់នៅរបស់នាយករដ្ឋមន្ត្រី និងក្រុមគ្រួសាររបស់នាយករដ្ឋមន្ត្រីឲ្យប្រកបដោយសុខុមាលភាព និងសេចក្តីថ្លៃថ្នូរ និងដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការបំពេញការងារទទួលខុសត្រូវចំពោះប្រទេសជាតិឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត។

*ការកំណត់អាណត្តិនាយករដ្ឋមន្ត្រីត្រឹមពីរអាណត្តិ ការមិនអនុញ្ញាតឲ្យនាយករដ្ឋមន្ត្រីបង្កើតក្រុមអង្គរក្សដោយខ្លួនឯង និងការតម្រូវឲ្យនាយករដ្ឋមន្ត្រីរស់នៅក្នុងនិវេសនដ្ឋានរដ្ឋនឹងអាចធានាថា នាយករដ្ឋមន្ត្រីមិនមានឱកាសណាមួយដើម្បីរៀបចំការដឹកនាំប្រទេសដោយប្រព័ន្ធដែលប្រមូលផ្តុំអំណាចបាននោះ។*

## ៤. បង្កើតតុលាការរដ្ឋបាល

បញ្ហាជាច្រើនដែលប្រជាពលរដ្ឋកំពុងជួបប្រទះក្នុងជីវភាពរស់នៅប្រចាំថ្ងៃនាពេលនេះគឺ មួយភាគធំពាក់ព័ន្ធនឹងការបំពេញការងាររបស់មន្ត្រីរដ្ឋាភិបាលដែលគ្មានប្រសិទ្ធភាព គ្មានប្រសិទ្ធផល និងគ្មានការទទួលខុសត្រូវ។ ក្រៅអំពីការប្រព្រឹត្តបទល្មើសជាក់ស្តែង ដូចដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ និងក្រម

រដ្ឋប្បវេណី កំហុសក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីរាជការជាច្រើនចេះតែបន្ត កើតឡើងដោយគ្មានទទួលរងការដាក់ទណ្ឌកម្ម។ មន្ត្រីរាជការដែលបំពេញការងារមិនត្រឹមត្រូវតាមក្រមសីលធម៌វិជ្ជាជីវៈ មិនថាវិជ្ជាជីវៈនោះជាគ្រូបង្រៀន ជាតុលាការ ឬជាប៉ូលីសនោះទេ ពួកគាត់នៅតែបន្តបំពេញការងាររបស់គាត់ ដើម្បីបានផលប្រយោជន៍ផ្ទាល់ខ្លួន ហើយជាទូទៅដោយការបំផ្លាញផលប្រយោជន៍ជាតិដោយគ្មានទោសពៃរ៍អ្វីសោះ ដោយសារតែគ្មានតុលាការរដ្ឋបាលដើម្បីវិនិច្ឆ័យទោសខុសក្រមសីលធម៌វិជ្ជាជីវៈរបស់ពួកគាត់។

តុលាការបច្ចុប្បន្ននេះមិនអាចចាប់កំហុស និង/ឬផ្តន្ទាទោសចំពោះមន្ត្រីរាជការដែលប្រព្រឹត្តកំហុសក្រមសីលធម៌វិជ្ជាជីវៈទេ។ កំហុសទាំងនេះ ទោះបីជាមើលទៅហាក់ដូចជាមិនធ្ងន់ធ្ងរក៏ដោយ ក៏វាគឺជាទង្វើដែលកំពុងតែបំផ្លាញប្រជាពលរដ្ឋខ្មែរជាទូទៅ។ ដូច្នេះ តុលាការរដ្ឋបាលដើរតួនាទីយ៉ាងសំខាន់សម្រាប់ប្តឹងមន្ត្រីរាជការលើរាល់ទង្វើរំលោភបំពាននានារបស់ពួកគាត់ក្នុងការបំពេញការងារ ឬដើម្បីឲ្យប្រជាពលរដ្ឋអាចប្តឹងទៅស្ថាប័ននេះឲ្យពិនិត្យភាពមិនប្រក្រតីនៃលិខិតស្នាម ឬសេចក្តីសម្រេចផ្សេងៗដែលចេញដោយអង្គភាពរដ្ឋបាលសាធារណៈគ្រប់លំដាប់។

*នៅពេលយន្តការនេះត្រូវបានប្រែក្លាយឲ្យទៅជាច្បាប់ ប្រជាពលរដ្ឋនឹងមានឱកាសគ្រប់ពេលដើម្បីប្តឹងមន្ត្រីរាជការដែលបំពេញការងារមិនត្រឹមត្រូវតាមក្រមសីលធម៌វិជ្ជាជីវៈ ឬប្តឹងជំទាស់ទៅនឹងភាពមិន ប្រក្រតីនៃលិខិតស្នាមរដ្ឋបាលនានារបស់រដ្ឋ។*

## ៥. ឋានន្តរសក្តិចាប់ពីឧត្តមសេនីយ៍យោធា និងនគរបាលត្រូវសុំសេចក្តីទុកចិត្តពីសភា

ឧត្តមសេនីយ៍យោធា និងនគរបាលគឺជាបុគ្គលដែលមានអំណាចខាងកងកម្លាំងប្រដាប់អាវុធដែលអាចបង្កគ្រោះថ្នាក់ចំពោះប្រទេសជាតិ តាមរយៈការធ្វើរដ្ឋប្រហារផ្តួលរំលំរបបគ្រប់គ្រងដែលពួកគាត់មិនពេញចិត្ត។ ប្រហាក់ប្រហែលទៅនឹងប្រធានកងអង្គរក្សការពារនាយករដ្ឋមន្ត្រីដែរ នាយយោធា និងនគរបាលដែលមានឋានន្តរសក្តិចាប់ពីឧត្តមសេនីយ៍ឡើងទៅត្រូវតែទទួលបានការសម្រេចផ្តល់សេចក្តីទុកចិត្តដោយសភាដែលជាតំណាងរបស់ប្រជាពលរដ្ឋ។

នេះគឺជាវិធានការដើម្បីធ្វើឲ្យសភាមានឥទ្ធិពលទៅលើនាយទាហាន និងនាយនគរបាលជាន់ខ្ពស់ដែលជាអ្នកបញ្ជាលើកងកម្លាំងប្រដាប់អាវុធ និងដើម្បីធានាថាកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទនឹងបំពេញតួនាទីរបស់ខ្លួនដោយឯករាជ្យដើម្បីរក្សាបូរណភាពទឹកដី សន្តិសុខ និងស្ថេរភាពសង្គម និងដើម្បីទប់ស្កាត់កុំឲ្យមានការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធជាឧបករណ៍ផ្តាច់ការ របស់គណបក្សដែលកំពុងកាន់អំណាច។

*នៅពេលយន្តការនេះត្រូវបានប្រែក្លាយឲ្យទៅជាច្បាប់ ឧត្តមសេនីយ៍យោធា និងនគរបាលនឹងត្រូវបានរំដោះឲ្យរួចផុតពីក្រញាំមេគណបក្ស ហើយអាចបំពេញការងារការពារសន្តិសុខជូនប្រជាពលរដ្ឋ និងប្រទេសជាតិដោយមនសិការវិជ្ជាជីវៈ និងការទទួលខុសត្រូវ។*

## ៦. អព្យាក្រឹតមន្ត្រីរាជការ

មន្ត្រីរាជការ រាប់បញ្ចូលទាំងមន្ត្រីរាជការក្នុងស្ថាប័នស៊ីវិល ឬកងកម្លាំងប្រដាប់អាវុធដែលស្ថិតក្នុងក្របខ័ណ្ឌសហលក្ខន្តិកៈមន្ត្រីរាជការរួមទាំងមន្ត្រីរាជការដែលបំពេញការងារជាមន្ត្រីក្របខ័ណ្ឌនៅគ្រប់ក្រសួងមន្ទីរការិយាល័យទាំងអស់របស់រដ្ឋ។

បច្ចុប្បន្ន មន្ត្រីរាជការត្រូវបានប្រើប្រាស់ដោយគណបក្សកំពុងកាន់អំណាចឲ្យបម្រើគណបក្សនេះប្រាសចាកពីក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។ មិនថាមន្ត្រីរាជការនៅថ្នាក់ណា នៅវិស័យអ្វីនោះទេឲ្យតែមន្ត្រីរាជការរាប់បញ្ចូលទាំងនាយកសាលារៀននៅបឋមសិក្សាឡើងទៅ តែងតែប្រើប្រាស់តួនា ទីរបស់គាត់ក្នុងនាមជាសកម្មជនរបស់គណបក្សកាន់អំណាចទោះ បីដោយការស្ម័គ្រចិត្តក្តី ដោយការគាបសង្កត់ក្តីដើម្បីគាបសង្កត់បុគ្គលិក ដែលនៅក្រោមឱវាទរបស់ខ្លួន ឬ ប្រជាពលរដ្ឋដែលនៅក្នុងសហគមន៍របស់ខ្លួនបន្ត។ ការដែលពួកគាត់ក្លាយជា សមាជិកសកម្មរបស់គណបក្សនយោបាយបែបនេះបណ្តាលឲ្យការបំពេញតួនា ទីរបស់គាត់មិនច្បាស់លាស់ គ្មានប្រសិទ្ធភាព និងមិនចាំបាច់ត្រូវប្រឈមនឹងការទទួលខុសត្រូវវិជ្ជាជីវៈអ្វីសោះ ដរាបណាគាត់បានទទួលទំនុកចិត្តពីថ្នាក់លើរបស់គណបក្ស ឬត្រូវបានមេគណបក្សកោតសរសើរក្នុងនាមរដ្ឋាភិបាលតាមរយៈការផ្តល់គ្រឿងឥស្សរិយយស ចំពោះស្នាដៃបំពេញការងារជូនជាតិមាតុភូមិក្នុងសកម្មភាពបម្រើគណបក្សនយោបាយ។

ការប្រើប្រាស់មន្ត្រីរាជការជាឧបករណ៍របស់គណបក្ស នាពេលបច្ចុប្បន្នមានលក្ខណៈធំធេង និងគ្រោះថ្នាក់ជាងពេលណាៗទាំងអស់។ មន្ត្រីរាជការទាំងនោះត្រូវបានគណបក្សនយោបាយបំពុលក្រោមរូបភាពនៃការបំប៉ន ដំឡើង

ឋានន្តរសក្តិ ឬការប្រគល់គ្រឿងឥស្សរិយយសជាបន្តបន្ទាប់ ទទួល ស្គាល់ស្នាដៃកសាងជាតិ ប៉ុន្តែតាមការពិតទៅជាការទទួលស្គាល់ចំពោះការបំពេញការងារជូនគណបក្សបានល្អប្រសើរ ឬដើម្បីជំរុញពួកគាត់ឲ្យងាកមកបំពេញការងារគណបក្សដើម្បីជាថ្នូរនឹងការដំឡើងបុណ្យសក្តិទៅវិញទេ។

ភាពអព្យាក្រឹតរបស់មន្ត្រីរាជការសំដៅទៅលើការបំពេញការងារដោយអព្យាក្រឹត មិនលម្អៀងទៅបម្រើគណបក្សនយោបាយណាមួយ។ គេអាចនិយាយម្យ៉ាងទៀតថា មន្ត្រីរាជការទាំងអស់មានសិទ្ធិគាំទ្រគណបក្សនយោបាយទៅតាមឆន្ទៈរបស់ខ្លួន ក៏ប៉ុន្តែទាំងការបំពេញការងារ ទាំងការដំឡើងឋានន្តរសក្តិមិនមានអ្វីពាក់ព័ន្ធនឹងកិច្ចការគណបក្សនោះទេ។

អព្យាក្រឹតមន្ត្រីរាជការគឺជាវិធានការដើម្បីធានាឲ្យមានការចាត់តាំងបែងចែកការងាររបស់មន្ត្រីរាជការឲ្យបានចំជំនាញ ស្របតាមសមត្ថភាព និងបទពិសោធការងារ និងផ្តល់សេចក្តីថ្លៃថ្នូរដល់មន្ត្រីរាជការដែលជាភ្នាក់ងា របស់រដ្ឋ។ ការនៅជាអព្យាក្រឹតនឹងជួយឲ្យមន្ត្រីរាជការបំពេញការងាររបស់ខ្លួនដោយឯករាជ្យ និងរំដោះពួកគាត់ឲ្យរួចផុតពីការគាបសង្កត់ពីគណបក្សដែលកំពុងកាន់អំណាច។ មន្ត្រីរាជការក៏មិនចាំបាច់ខ្វល់ ខ្វាយអំពី ការបាត់បង់មុខតំណែង ក្រោយពីការរុះរើគណៈរដ្ឋមន្ត្រី និង/ឬក្រោយពេលបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសម្រាប់អាណត្តិថ្មីម្តងៗ។

ប្រហាក់ប្រហែលនឹងមន្ត្រីរាជការដែរ ព្រះចៅអធិការ និងព្រះសង្ឃមួយចំនួនធំនៅតាមវត្តអារាមនានា ក៏ជាបណ្តាញរបស់គណបក្សដែលកំពុងកាន់ ដ្ឋាភិបាល

ដែរ។ ពួកគាត់បានការពារគណបក្សដែលកំពុងកាន់អំណាចផង គាបសង្កត់ព្រះសង្ឃណាដែលមាននិន្នាការនយោបាយផ្ទុយផង និងជួយឃោសនាឲ្យប្រជាពលរដ្ឋគាំទ្រគណបក្សកាន់អំណាចផង។ ព្រះសង្ឃគួរមានភាពអព្យាក្រឹត មិនគួរទៅបម្រើនិន្នាការនយោបាយរបស់គណបក្សមួយដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួនដោយគ្មានហិរិ និងឱត្តប្បៈក្នុងខ្លួននោះទេ។

*នៅពេលយន្តការនេះត្រូវបានប្រែក្លាយឲ្យទៅជាច្បាប់ មន្ត្រីរាជការទាំងអស់នឹងត្រូវបានរំដោះឲ្យចេញពីក្រញាំមេគណបក្សទាំងថ្នាក់កណ្តាល ទាំងថ្នាក់មូលដ្ឋាន និងអាចធានាថា ពួកគាត់ត្រូវតែបំពេញកិច្ចការដោយគោរពទៅតាមក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួននីមួយៗ និងប្រកបដោយការទទួលខុសត្រូវខ្ពស់ចំពោះអ្នកដែលទទួលសេវាពីពួកគាត់ ពោលគឺប្រជាពលរដ្ឋ មិនមែនចំពោះគណបក្សដូចពេលបច្ចុប្បន្ននេះទេ។*

## ៧. បោះឆ្នោតជ្រើសរើស និងបោះឆ្នោតដកតំណាងគ្រប់លំដាប់ - ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ ខេត្ត/រាជធានី - ដោយប្រជាពលរដ្ឋផ្ទាល់

រដ្ឋបាលគ្រប់គ្រងនៅកម្ពុជាត្រូវបានបែងចែកជាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលរួមមានថ្នាក់ខេត្ត/រាជធានី ស្រុក និងឃុំ។ សព្វថ្ងៃនេះ កម្ពុជាមានការរៀបចំការបោះឆ្នោតសកលថ្នាក់ជាតិ គឺការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងការបោះឆ្នោតសកលថ្នាក់ក្រោមជាតិ គឺការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់។ ប្រហាក់ប្រហែលនឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រដែរ ប្រព័ន្ធបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់បច្ចុប្បន្នគឺជាការបោះឆ្នោតឲ្យគណបក្ស ហើយគណបក្សជាអ្នកចាត់តាំងបេក្ខភាពថាតើអ្នកណាជាអ្នកត្រូវឈរឈ្មោះនៅលំដាប់លេខរៀងលេខ១ លេខរៀងលេខ២

និងលេខរៀងជាបន្តបន្ទាប់ទៀត។ ដូចនេះ ប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសគណបក្ស មិនមែនជ្រើសរើសតំណាងរបស់ខ្លួននោះទេ។

ដើម្បីឲ្យប្រជាធិបតេយ្យកាន់តែមានលក្ខណៈទូលំទូលាយ និងឲ្យសេវាសាធារណៈរបស់រដ្ឋអាចឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋតាមមូលដ្ឋានកាន់តែមានប្រសិទ្ធភាព ការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាក្រុង/ស្រុក/ខណ្ឌ និងក្រុមប្រឹក្សាខេត្ត/រាជធានីគឺត្រូវតែធ្វើជាចាំបាច់ឲ្យបានទៀងទាត់ និងមានលក្ខណៈដូចការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រយ៉ាងដូច្នោះដែរ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ និងខេត្ត/រាជធានីដោយប្រព័ន្ធបច្ចុប្បន្ន គឺជាការជ្រើសរើសគណបក្ស។ តំណាងចេញពីប្រព័ន្ធដូចនេះមិនបានធ្វើការឆ្លើយតប ដល់ផលប្រយោជន៍ប្រជាពលរដ្ឋមូលដ្ឋានទេ ពីព្រោះពួកគាត់ត្រូវធ្វើការបម្រើគណបក្សដែលជាអ្នកសម្រេចជោគវាសនារបស់ពួកគាត់។ ដូច្នេះ ការផ្លាស់ប្តូរប្រព័ន្ធពីការបោះឆ្នោតជ្រើសរើសគណបក្សមកជាការបោះឆ្នោតជ្រើសរើសបុគ្គលដោយផ្ទាល់ គឺជាវិធានការចាំបាច់ដើម្បីឲ្យពួកគាត់ផ្តល់សេវាជូនប្រជាពលរដ្ឋ ដោយមិនខ្លាចរអែងមេគណបក្ស។ តំណាងនៅកម្រិតឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ និងខេត្ត/រាជធានី ដែលត្រូវបោះឆ្នោតជ្រើសរើសដោយផ្ទាល់ដោយប្រជាពលរដ្ឋ នឹងមិនរងសម្ពាធរបស់មេគណបក្សទៀតទេ។ នៅពេលនោះ ពួកគាត់នឹងងាកមកបំពេញការងារដែលច្បាប់បានកំណត់ និងទទួលខុសត្រូវចំពោះប្រជាពលរដ្ឋមូលដ្ឋានវិញម្តង។ ទន្ទឹមនឹងការបោះឆ្នោតជ្រើសរើសដោយផ្ទាល់ ប្រជាពលរដ្ឋក៏ជាអ្នកបោះឆ្នោតទម្លាក់តំណាង

ទាំងនោះវិញ នៅពេលណាដែលតំណាងទាំងនោះបំពេញការងាររបស់ពួកគាត់ ពុំមានប្រសិទ្ធភាព។

វិធានការនេះក៏ដើម្បីធ្វើឲ្យតំណាងប្រជាពលរដ្ឋគ្រប់លំដាប់ - ឃុំ/សង្កាត់ក្រុង/ស្រុក/ខណ្ឌ និងខេត្ត/រាជធានីមានការទទួលខុសត្រូវផ្ទាល់ចំ ពោះមុខប្រជាពលរដ្ឋ ដែលជាម្ចាស់អំណាច និងដើម្បីកាត់បន្ថយការបញ្ជាតាមខ្សែរយៈបក្សពួក ពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន។ តំណាងនៅគ្រប់លំដាប់នឹងយកចិត្តទុកដាក់បំពេញការងារជូនប្រជាពលរដ្ឋតាមមូលដ្ឋាន ជាជាងបម្រើគណបក្សដែលកំពុងកាន់អំណាច។

*នៅពេលយន្តការនេះត្រូវបានប្រែក្លាយទៅជាច្បាប់ តំណាងគ្រប់លំដាប់ - ឃុំ/សង្កាត់ ក្រុង/ស្រុក/ខណ្ឌ ខេត្ត/រាជធានី - នឹងត្រូវបានជ្រើសរើសដោយប្រជាពលរដ្ឋផ្ទាល់ឲ្យទៅទទួលខុសត្រូវការងារតាមមុខនាទីនីមួយៗ ហើយពួកគាត់ក៏នឹងត្រូវបោះឆ្នោតទម្លាក់ដោយប្រជាពលរដ្ឋវិញដែរ។ ពួកគាត់នឹងទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ មិនមែនចំពោះគណបក្សដូចបច្ចុប្បន្ន។*

## ៨. បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រតាមប្រព័ន្ធចម្រុះ

ដូចបានលើកឡើងខាងលើរួចមកហើយថា ប្រព័ន្ធបោះឆ្នោតជ្រើសរើសតំណាងរាស្ត្របច្ចុប្បន្ន គឺប្រព័ន្ធសមាមាត្រដែលប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសគណបក្សនយោបាយណាមួយដែលខ្លួនពេញចិត្តចូលរួមក្នុងការបោះឆ្នោតនៅក្នុងខេត្ត រាជធានីរបស់គាត់។ មេគណបក្សជាអ្នកជ្រើសរើសថាតើបេក្ខជនមួយណាជាអ្នកឈរឈ្មោះនៅលំដាប់លេខរៀងលេខ១ លេខរៀងលេខ២ និងលេខរៀងបន្តបន្ទាប់។ ប្រព័ន្ធបែបនេះគឺផ្តល់អំណាចឲ្យមេគណបក្សទាំងស្រុងជាអ្នក

កំណត់ថាតើអ្នកណានឹងក្លាយជាតំណាងរាស្ត្រ នៅតាមមណ្ឌលនីមួយៗ។ អាស្រ័យហេតុនេះ បេក្ខជនតំណាងរាស្ត្រនឹងធ្វើអ្វីៗដើម្បីផ្គាប់ផ្គុនមេគណបក្សឲ្យគាត់អាចឈរឈ្មោះនៅលំដាប់លេខរៀងខ្ពស់ដែលងាយនឹងជាប់ជាតំណាងរាស្ត្រ បើទោះបីជាប្រជាពលរដ្ឋមិនស្គាល់បេក្ខជនតំណាងរាស្ត្រនោះសោះក៏ដោយ។

ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រតាមប្រព័ន្ធចម្រុះ គឺជាការបោះឆ្នោតឲ្យគណបក្សផង និងឲ្យបុគ្គលដែលឈរឈ្មោះឲ្យគណបក្សនោះផង។ ប្រព័ន្ធបោះឆ្នោតនេះនឹងធានាថា បុគ្គលដែលចង់ឈរឈ្មោះជាតំណាងរាស្ត្រត្រូវតែឃោសនា ដោយផ្ទាល់នៅតាមមូលដ្ឋានដែលខ្លួនចង់ធ្វើជាតំណាងរាស្ត្រដោយមិនចាំបាច់ឲ្យមេគណបក្សចាត់តាំងខ្លួននោះឡើយ។ ប្រព័ន្ធនេះនឹងជ្រើសរើសបានតំណាងរាស្ត្រដែលឯករាជ្យ និងមានសេរីភាពគ្រប់គ្រាន់ដោយគ្មានរងសម្ពាធពីមេគណបក្សនោះ បើទោះបីជាពួកគាត់ឈរឈ្មោះឲ្យប្រជាពលរដ្ឋបោះឆ្នោតតាមរយៈគណបក្សក៏ដោយ។ តំណាងរាស្ត្រអាចបំពេញការងារជួយកែតម្រង់រដ្ឋាភិបាលយ៉ាងមានប្រសិទ្ធភាព និងរៀបចំធ្វើច្បាប់ដើម្បីផលប្រយោជន៍ជាតិ និងផលប្រយោជន៍ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតពិតៗ។

*នៅពេលដែលប្រព័ន្ធបោះឆ្នោតចម្រុះត្រូវបានដាក់ឲ្យអនុវត្តដើម្បីបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ នៅពេលនោះតំណាងរាស្ត្រគឺជាតំណាងប្រជាពលរដ្ឋពិតប្រាកដ។ ដោយហេតុថា វាសនារបស់តំណាងរាស្ត្រស្ថិតនៅក្នុងកណ្តាប់ដៃប្រជាពលរដ្ឋ តំណាងរាស្ត្រនឹងចូលរួមអនុម័តច្បាប់ដែលឆ្លើយតបផលប្រយោជន៍ប្រជាពលរដ្ឋ និងតាមដានដំណើរការអនុវត្តច្បាប់ទៅតាមតួនាទី និងភារកិច្ច ហើយលែងដាក់ខ្លួនជាឧបករណ៍នយោបាយរបស់មេគណបក្សទៀត។*

## ច្បាប់ដែលកើតចេញពីយន្តការប្រាំបីចំណុចអាច ៖

- កាត់បន្ថយអំណាច និងឥទ្ធិពលនាយករដ្ឋមន្ត្រីធ្វើឲ្យមានតុល្យភាព អំណាចទាំងបីគឺអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ និងធ្វើឲ្យមានតុល្យភាពអំណាចរវាងអំណាចរដ្ឋ និងអំណាចប្រជាពលរដ្ឋ
- រំដោះសមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា តំណាងប្រជាពលរដ្ឋគ្រប់លំដាប់ និងមន្ត្រីរាជការគ្រប់រូបឲ្យរួចផុតពីការធ្វើជាឧបករណ៍បម្រើគណបក្សនយោបាយ ជាពិសេសគណបក្ស ដែលកំពុងកាន់អំណាច
- រំដោះនាយករដ្ឋមន្ត្រីឲ្យរួចផុតពីការទទួលខុសត្រូវតែម្នាក់ឯង ចំពោះជោគវាសនាប្រទេសជាតិ និងដាក់ឲ្យមន្ត្រីរាជការ និងមន្ត្រីនយោបាយគ្រប់លំដាប់ឲ្យទទួលខុសត្រូវចំពោះវិជ្ជាជីវៈរបស់ខ្លួន ទាំងខាងផ្លូវច្បាប់ និងខាងមនសិការ
- ផ្តល់ឱកាសឲ្យប្រជាពលរដ្ឋធ្វើម្ចាស់ជាអចិន្ត្រៃយ៍ លើតំណាងគ្រប់លំដាប់ តាមរយៈការបោះឆ្នោតដោយចំពោះ ទាំងពេលបោះឆ្នោតគាំទ្រ និងពេលបោះឆ្នោតទម្លាក់
- ជាវិធានការមានប្រសិទ្ធភាព ដើម្បីដោះស្រាយបញ្ហាសង្គមសព្វបែបយ៉ាង ដូចជាបញ្ហាពុករលួយ បញ្ហាអយុត្តិធម៌ក្នុងប្រព័ន្ធតុលាការ បញ្ហាជីវភាពក្រីក្រ បញ្ហាការរឹបអូសដីធ្លី បញ្ហាអសន្តិសុខសង្គម និងបញ្ហាសព្វបែបយ៉ាងទៀតដែលប្រជាពលរដ្ឋកំពុងជួបប្រទះនាពេលនេះ

- ជាច្បាប់ជំរុញឲ្យស្ថាប័ន និងបុគ្គលពាក់ព័ន្ធនានាឲ្យអនុវត្តច្បាប់ដទៃទៀត ឬបំពេញតួនាទី និងភារកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់ដើម្បីឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋទូទៅ ដោយគ្មានការរើសអើង
- ជាវិធានការបញ្ចប់ការគ្រប់គ្រងស្ថាប័ន និងស្រុកទេសតាមប្រព័ន្ធដែលប្រមូលផ្តុំលើបុគ្គលម្នាក់ ឬមួយក្រុម មកជាការគ្រប់គ្រងស្ថាប័ន និងស្រុកទេសតាមប្រព័ន្ធដែលពង្រាយអំណាចតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន
- បង្កលក្ខណៈឲ្យប្រជាពលរដ្ឋគ្រប់រូបមកពីគ្រប់និន្នាការនយោបាយមានឱកាសចូលរួមបង្កើតសង្គមប្រជាធិបតេយ្យពិតប្រាកដ និងអភិវឌ្ឍស្រុកទេសដោយការយល់ដឹង ដោយការទទួលខុសត្រូវ និងដោយមោទនភាព
- បញ្ចប់វប្បធម៌បែងចែកបក្ខពួកនយោបាយនៅតាមស្ថាប័នរដ្ឋ និងនៅតាមមូលដ្ឋានក្នុងចំណោមប្រជាពលរដ្ឋ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងព្រះសង្ឃ
- ជំរុញឲ្យមានសាមគ្គីភាព ការមានទំនុកចិត្ត និងការជួយគ្នាទៅវិញទៅមក ដោយឈរលើបាតគ្រឹះសុចរិតរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងប្រទេសប្រកាន់យករបបប្រជាធិបតេយ្យ និងបដិបត្តិព្រះធម៌ដែលជាមេរៀនត្រាស់ដឹងរបស់ព្រះពុទ្ធ

- បញ្ចប់វប្បធម៌នៃការដឹកនាំតាមឆន្ទៈរបស់មេដឹកនាំគ្រប់លំដាប់មកជាការដឹកនាំតាមប្រព័ន្ធបែងចែកតួនាទីច្បាស់លាស់រវាងស្ថាប័ននីមួយ ៗ និងមានការទទួលខុសត្រូវចំពោះមុខច្បាប់

- បញ្ចប់វប្បធម៌នៃការគិតថា នយោបាយគឺជាកិច្ចការចិញ្ចឹមជីវិតរបស់អ្នកនយោបាយ ឬរបស់អ្នកធំដែលកំពុងតែកាន់កាប់អំណាចរដ្ឋ ហើយបណ្តុះគំនិតចូលរួមធ្វើនយោបាយក្នុងចំណោមប្រជាពលរដ្ឋគ្រប់ៗរូប

- ជាប្រព័ន្ធសម្រាប់សម្រិតសម្រាំងយកតែអ្នកមានបេះដូងសុចរិត ចង់ជួយអ្នកដទៃ និងមានទស្សនវិស័យច្បាស់លាស់សម្រាប់ការអភិវឌ្ឍជាតិឲ្យមកធ្វើជាកម្លាំងស្នូលក្នុងចលនានយោបាយរបស់គណបក្ស

- ធានាឲ្យប្រជាពលរដ្ឋមានឱកាសស្មើៗគ្នាចំពោះមុខច្បាប់ដើម្បីប្រកបរបរចិញ្ចឹមជីវិត និងទទួលបានផលទៅតាមកម្លាំងកាយ កម្លាំងប្រាជ្ញា និងទុនវិនិយោគរៀងៗខ្លួន

- ក្លាយជាមរតកគ្រប់គ្រងសង្គមតាមបែបប្រជាធិបតេយ្យដែលផ្តល់សេចក្តីសុខ និងរីកចម្រើនយ៉ាងថ្លៃថ្នូរដល់កូនខ្មែរលើគ្រប់វិស័យ

- ជាមធ្យោបាយមានប្រសិទ្ធភាពទប់ស្កាត់មិនឲ្យកម្ពុជាក្លាយជាប្រទេសដែលរងការគំរាមកំហែងដែលនឹងអាចឈានដល់ការបាត់បង់ទឹកដី ឬពូជសាសន៍ពីសំណាក់ប្រទេសជិតខាង

*ការបកស្រាយលម្អិតនៃចំណុចនីមួយៗខាងលើនេះ មាននៅក្នុងសារសំឡេងដែលអាចរកបាននៅទីស្នាក់ការ ឬគេហទំព័រគណបក្សសម្ព័ន្ធប្រជាធិបតេយ្យ។*

នៅពេលមានច្បាប់កើតចេញពីយន្តការប្រាំបីចំណុចមកអនុវត្តនៅកម្ពុជាទាំងប្រមុខដឹកនាំក្រុម ទាំងអ្នកគាំទ្រ និងអ្នកស្ម័គ្រចិត្តរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យនឹងមិនបានទទួលផល ជាពិសេសអ្វីដែលជាផលប្រយោជន៍ផ្ទាល់ខ្លួនពីសកម្មភាពនយោបាយរបស់ខ្លួននោះទេ។ ប្រសិនបើមានសមាជិកគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យណាត្រូវចូលកាន់ការងារចាត់ចែងកិច្ចការស្រុកទេស មិនថាការងារនោះនៅត្រឹមកម្រិតណានោះទេ គ្មានទេពាក្យថាលាភសក្ការៈផ្ទាល់ខ្លួនខុសច្បាប់ដែលបានមកពីការកាន់តួនាទីនោះ ពីព្រោះថាអ្នកដែលកាន់តួនាទីនោះគឺមានតែការទទួលខុសត្រូវតែប៉ុណ្ណោះ។ ដោយសារមានការអនុវត្តប្រព័ន្ធបង្រួមអំណាចរដ្ឋ ភាពអយុត្តិធម៌ក្នុងសង្គម ទាំងអយុត្តិធម៌នៃការបែងចែកភោគផលធម្មជាតិ និងទាំងអយុត្តិធម៌ក្នុងប្រព័ន្ធតុលាការនឹងត្រូវកាត់បន្ថយ ឬលុបបំបាត់ជាបណ្តើរៗ។ ជាលទ្ធផលនៃការអនុវត្តប្រព័ន្ធនេះ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យសង្ឃឹមយ៉ាងមុតមាំថា ទាំងមន្ត្រីរាជការ ទាំងមន្ត្រីរដ្ឋបាលសាធារណៈដែលកាន់មុខតំណែងតាមអាណត្តិ ទាំងអ្នករកស៊ីធំតូចទាំងឡាយ ទាំងកសិករ និងកម្មករ នឹងទទួលបានផលប្រយោជន៍យ៉ាងច្រើនសន្ធឹកសន្ធាប់ពីប្រព័ន្ធនៃការគ្រប់គ្រងដែលបុគ្គលម្នាក់ៗបំពេញតួនាទីត្រឹមជាតំណាងទៅតាមតួនាទីរបស់ខ្លួន ទាំងនៅចំពោះមុខច្បាប់ និងនៅចំពោះមុខប្រជាពលរដ្ឋដែលជាម្ចាស់ប្រទេស។ មានតែមនុស្សមួយចំនួនតូចប៉ុណ្ណោះ រួមមានមន្ត្រីរដ្ឋាភិបាល និងពាណិជ្ជ រមួយចំនួនដែលកំពុងតែបានប្រយោជន៍ពីការប្រព្រឹត្តមិនប្រក្រតីខុសច្បាប់រដ្ឋ ឬច្បាប់ធម្មជាតិ ទោះក្នុងកិច្ចការងាររដ្ឋក្តី ក្នុងកិច្ចការរកស៊ីធំតូចក្តី ឬទោះក្នុងស្ថាប័ន ព្រះសង្ឃក្តីទើបទទួលរងផលប៉ះពាល់នៃការបាត់បង់ប្រយោជន៍ផ្ទាល់ខ្លួន ដោយសារសកម្មភាពនយោបាយរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។

កាតព្វកិច្ចនៃការចូលរួមរបស់ប្រជាពលរដ្ឋ

តួនាទីគន្លឹះរបស់ប្រជាពលរដ្ឋនៅក្នុងការកសាងសង្គមប្រជាធិបតេយ្យគឺការចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពសាធារណៈក្នុងសង្គម។ ប្រជាពលរដ្ឋមានកាតព្វកិច្ចតាមដានព័ត៌មានអំពីបញ្ហាសង្គម និងតាមដានដោយការវិភាគពិចារណាលើរាល់សកម្មភាពរបស់គណបក្សនយោបាយទាំងអស់ដើម្បីឲ្យខ្លួនអាចប្រើប្រាស់ឆ្នោតមួយសន្លឹកទៅសម្តែងការគាំទ្រ ប្រកបដោយអត្ថន័យត្រឹមត្រូវពិតប្រាកដជាជាងការដោះដូរជាមួយនឹងលាភសក្ការៈបន្តិចបន្តួច ដែលផ្តល់ដោយគណបក្ស ទោះជាផ្ទាល់ក្តី ឬគ្រាន់តែជាការសន្យាក្តី។

ការចូលរួមបោះឆ្នោតគឺជាករណីយកិច្ចមិនអាចខ្វះបាន របស់ប្រជាពលរដ្ឋទូទៅ។ ដើម្បីបោះឆ្នោតដោយការយល់ដឹង និងការទទួលខុសត្រូវ ប្រជាពលរដ្ឋម្នាក់ៗត្រូវតែតាមដានគោលនយោបាយរបស់គណបក្សនយោបាយនីមួយៗ ហើយបន្ទាប់មកធ្វើសេចក្តីសម្រេចបោះឆ្នោតគាំទ្រទស្សនវិស័យដឹកនាំស្រុកទេសរបស់គណបក្សណាមួយដែលអាចដោះស្រាយបញ្ហាស្រុក ទេស ឬបញ្ហារបស់ប្រជាពលរដ្ឋបាន។

ការចូលរួមអាចរួមបញ្ចូលទាំងការចូលរួមឃោសនាគាំទ្រគណបក្សនយោបាយ ឬបុគ្គលដែលឈរឈ្មោះឲ្យគណបក្សនយោបាយ ចូលរួមជជែកពិភាក្សាជេញដោលបញ្ហាសាធារណៈ ចូលរួមកិច្ចប្រជុំតាមសហគមន៍ ទាមទារប្រឆាំងរដ្ឋាភិបាល។ល។ ទម្រង់នៃការចូលរួមអាចធ្វើឡើងតាមរយៈការធ្វើជាសមាជិកសកម្មរបស់អង្គការក្រៅរដ្ឋាភិបាលដែលយើងហៅថា "សង្គមស៊ីវិល"។ សង្គមស៊ីវិលទាំងនេះតំណាងផលប្រយោជន៍ និងទស្សនៈនយោបាយផ្សេងៗគ្នា

ដូចជាកសិករ កម្មករ គ្រូពេទ្យ គ្រូបង្រៀន អ្នករកស៊ី អ្នកសាសនា សិស្សនិស្សិត សកម្មជនសិទ្ធិមនុស្ស។ ល។

ដើម្បីឲ្យមានការចូលរួម វាទាមទារឲ្យមានការខិតខំប្រឹងប្រែងដោយស្ថាប័នពាក់ព័ន្ធ បង្ហាត់បង្រៀនប្រជាពលរដ្ឋអំពីប្រជាធិបតេយ្យ សិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋក្នុងសង្គមប្រជាធិបតេយ្យ លើកកម្ពស់ជំនាញវិភាគនយោបាយ ហើយគៀងគរប្រជាពលរដ្ឋឲ្យចូលរួមក្នុងសកម្មភាពសាធារណៈក្នុងសង្គមឲ្យបានជាប់ជាប្រចាំ។ រាល់ការចូលរួមទាំងអស់នៅក្នុងសង្គមប្រជាធិបតេយ្យត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត។ គ្មានអ្នកណាបង្ខិតបង្ខំអ្នកណាឲ្យចូលរួមក្នុងសកម្មភាពសង្គមប្រឆាំងនឹងសុឆន្ទៈរបស់បុគ្គលនោះទេ។ ការចូលរួមដោយការទទួលខុសត្រូវ និងមានគោលដៅច្បាស់លាស់ឈានទៅសម្រេចផលប្រយោជន៍រួម មុនផលប្រយោជន៍បុគ្គលទើបជាការចូលរួមពិតប្រាកដដែលផ្ទុយពីការដើរតាម។

គណបក្សនយោបាយគឺជាអង្គការនយោបាយដ៏សំខាន់នៅក្នុងសង្គមប្រជាធិបតេយ្យ ហើយសង្គមប្រជាធិបតេយ្យនឹងរឹងរឹតតែខ្លាំងឡើង នៅពេលណាប្រជាពលរដ្ឋមានការយល់ដឹងច្បាស់លាស់ និងក្លាយជាសមាជិកសកម្មក្នុងគណបក្សនយោបាយ។ ទោះបីជាយ៉ាងណាក្តី ចូរចាំថា គ្មានប្រជាពលរដ្ឋណាម្នាក់ត្រូវគាំទ្រគណបក្សនយោបាយណាមួយដោយសារតែខ្លួនទទួលការគាបសង្កត់ ការគំរាមកំហែង និងការដោះដូរទេ ទោះដោយមធ្យោបាយណាក៏ដោយ។ នៅក្នុងសង្គមប្រជាធិបតេយ្យប្រជាពលរដ្ឋមានសេរីភាពពេញលេញដើម្បីជ្រើសរើសគណបក្សនយោបាយដែលខ្លួនពេញចិត្តដែលអាចមានការប្រែប្រួលទៅតាមកាលៈទេសៈរបស់បុគ្គល ឬគ្រួសារ

នីមួយ ៗ។ ការគាំទ្រគណបក្សនេះនៅអាណត្តិនេះ និងគាំទ្រគណបក្សនោះនៅអាណត្តិក្រោយគឺជារឿងធម្មតា។

ប្រជាពលរដ្ឋខ្មែរមិនធ្លាប់ចូលរួមក្នុងសកម្មភាពនយោបាយ ដោយការយល់ដឹងច្បាស់លាស់នោះទេ ហើយនេះគឺជាដើមចមនៃបញ្ហាសព្វបែបយ៉ាង។ ជាទូទៅការចូលរួមរបស់ពួកគាត់មានតែពីរទម្រង់ប៉ុណ្ណោះ។ ទីមួយ គាត់ចូលរួមជាមួយអ្នកខ្លាំង ឬអ្នកឈ្នះដើម្បីលាភសក្ការៈផ្ទាល់ខ្លួន ឬដើម្បីរួចផុតពីការគំរាមកំហែងរួមទាំងការគំរាមកំហែងអាយុជីវិត សេដ្ឋកិច្ច ឬការងារ។ ទីពីរ ប្រជាពលរដ្ឋចូលរួមជាមួយក្រុមប្រឆាំងដោយសារតែគាត់មិនពេញចិត្តនឹងក្រុមកាន់អំណាច។ តែទោះបីជាយ៉ាងនេះក៏ដោយ ក៏ពួកគាត់មិនដឹងថាតើក្រុមប្រឆាំងនោះកំពុងនាំពួកគាត់ទៅទីណាដោយវិធីណានោះទេ។ ការចូលរួមក្នុងទម្រង់ទាំងពីរនេះគឺជាការចូលរួមដង្ហែរអ្នកនយោបាយឲ្យសោយសុខលើទុក្ខសោករបស់ខ្លួនដែលជាម្ចាស់ប្រទេស។

គ្មានប្រជាពលរដ្ឋនៅក្នុងប្រទេសប្រជាធិបតេយ្យណាមិនធ្វើនយោបាយនោះទេ។ ប្រសិនបើប្រជាពលរដ្ឋមិនបោះឆ្នោតដោយការយល់ដឹងច្បាស់លាស់ទេ ប្រជាពលរដ្ឋនោះមិនត្រូវនិយាយថា ខ្លួនកំពុងតែរស់នៅក្នុងប្រទេសប្រកាន់យករបបប្រជាធិបតេយ្យឡើយ ពីព្រោះខ្លួនកំពុងតែគាំទ្រចលនានយោបាយមួយនៅក្នុងប្រទេសនោះ ដោយគ្មានការយល់ដឹងក្នុងនាមជាប្រជាពលរដ្ឋម្ចា ស់ប្រទេសម្នាក់ទាល់តែសោះ។ ចូរចាំថា បើអ្នកមិនចូលរួមធ្វើនយោបាយសុចរិតដែលជាប្រយោជន៍សម្រាប់ប្រទេសជាតិទេ អ្នកកំពុងតែទុកឱកាសឲ្យអ្នកនយោបាយទុច្ចរិតឃ្លំ ញជីវិតអ្នក ពូជសាសន៍អ្នក និងប្រទេសអ្នកជាក់ជាមិនខាន។

គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យគឺជាយានសម្រាប់ឲ្យប្រជាពលរដ្ឋខ្មែរមកពីគ្រប់និន្នាការនយោបាយដែលមានបេះដូងស្រលាញ់ជាតិ និងប្រជាពលរដ្ឋខ្លួនពិតប្រាកដ មានឱកាសចូលរួមបង្កើតសង្គមមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់។ ប្រសិនបើគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យមិនអាចកៀងគរធនធានមនុស្សចំនួនត្រឹមតែ២០០ ឬ៣០០នាក់ នៅដំណាក់កាលដំបូងដែលអ្នកទាំងនោះមានបេះដូងជួយសង្គ្រោះជាតិ និងមានចំណេះដឹងដើម្បីចូលរួមក្នុងចលនានយោបាយ ឈានទៅប្រែក្លាយ **"កម្ពុជាទៅជាមាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់"** នៅក្នុងជំនាន់នេះបាន វាគឺជាវាសនាអាក្រក់នៃទឹកដីសុវណ្ណភូមិមួយនេះ។ លើសពីនេះទៀតសូមអ្នកបញ្ចប់ការនិយាយអំពីអតីតកាលបែបស្តាយស្រណោះ ដូចជាការនិយាយអំពីការបាត់បង់ទឹកដីកម្ពុជាក្រោម និងការបាត់បង់ធនធានធម្មជាតិ ក៏ដូចជាការនិយាយអំពីការព្រួយបារម្ភអំពីការឈ្លានពានរបស់បរទេស តាមរូបភាពថ្មី។ កូនចៅជំនាន់ក្រោយរបស់អ្នកនឹងចោទប្រកាន់អ្នកដូចគ្នា ក្រោយពេលអ្នកបាត់បង់ជីវិតទៅ។

តាមគតិបណ្ឌិតរបស់អ្នកប្រាជ្ញអាល់ប៊ឺត អាញស្តាញ (Albert Einstein) ដែលថា ពិភពលោកនេះមិនមែនត្រូវបានបំផ្លាញដោយមនុស្សអាក្រក់តែប៉ុណ្ណោះទេ ប៉ុន្តែវាក៏ត្រូវបានបំផ្លាញដោយមនុស្សល្អដែលឈរមើលការបំផ្លាញពិភពលោកដោយមនុស្សអាក្រក់ផងដែរ។

## ៣
## ឥរិយាបថនយោបាយ

ការធ្វើនយោបាយដោយភាពត្រឹមត្រូវគឺជាការងាររបស់បុគ្គលដែលចង់ធ្វើការដើម្បីប្រជាពលរដ្ឋ និងអភិវឌ្ឍប្រទេសតាមទស្សនវិស័យនៃការដឹកនាំរដ្ឋដែលខ្លួនយល់ឃើញថាត្រឹមត្រូវសម្រាប់កាលៈទេសៈរបស់ប្រទេស។

ពិតណាស់ ប្រទេសដែលប្រកាន់យកប្រព័ន្ធគ្រប់គ្រងរដ្ឋតាមលទ្ធិប្រជាធិបតេយ្យដូចប្រទេសកម្ពុជា ការផ្លាស់ប្តូររដ្ឋាភិបាលត្រូវតែធ្វើឡើងតាមរយៈការបោះឆ្នោត។ ការបោះឆ្នោតគឺជាឱកាសសម្រាប់ឲ្យគណបក្សនយោបាយចូលរួមប្រកួតប្រជែងទស្សនវិស័យនៃការដឹកនាំស្រុកទេស ប្រសិនបើគណបក្សរបស់ខ្លួនទទួលបានសំឡេងគាំទ្រគ្រប់គ្រាន់ពីម្ចាស់ឆ្នោតដោយខ្លួនឯងដាច់ខាត ឬដោយការចងសម្ព័ន្ធភាពជាមួយគណបក្សផ្សេងទៀត។

ដូច្នេះ រាល់សកម្មភាពរបស់អ្នកនយោបាយគ្រប់ពេលទាំងអស់ត្រូវតែមានតម្លាភាព សុចរិតភាព និងការទទួលខុសត្រូវជាបាតគ្រឹះ ទាំងកាយ វាចា និងចិត្ត។ អ្នកនយោបាយត្រូវយល់ដឹង និងប្រកាន់ឲ្យបានខ្ជាប់ខ្ជួនថា ខ្លួនចូលរួមបង្កើតគណបក្សនយោបាយមួយនេះ ឬមួយនោះឡើងក្នុងគោលបំណងទៅដឹកនាំស្រុកទេសតាមទស្សនវិស័យរបស់ខ្លួនដែលជាទូទៅខុសពីទស្សនវិស័យរបស់ក្រុមផ្សេងដោយចាប់ផ្តើមពីការពន្យល់ប្រជាពលរដ្ឋតាមគ្រប់មធ្យោបាយឲ្យបានយល់ដឹង និងគាំទ្រតាមរយៈសន្លឹកឆ្នោតរបស់ពួកគាត់។ សកម្មភាពនយោបាយដែលមានតម្លាភាព សុចរិតភាព និងការទទួលខុសត្រូវគឺជា

សកម្មភាពដែលមិនបង្កអរិភាព ឬគ្រោះថ្នាក់ចំពោះប្រជាពលរដ្ឋ ទោះបីជាពួកគាត់គាំទ្រ ឬមិនគាំទ្រគណបក្សនោះក៏ដោយ។

ផ្ដើមចេញពីបេះដូងជួយសង្គ្រោះ សកម្មភាពរបស់អ្នកនយោបាយត្រូវតែជាសកម្មភាពដែលធ្វើឡើងដោយមនោសុចរិត ប្រាសចាកភាពអាត្មានិយម។ ខាងក្រោមនេះគឺជាហេតុផលដែលអ្នកនយោបាយត្រូវតែ ″ធ្វើនយោបាយដោយសុចរិត″ ដើម្បីធានាបាននូវការគាំទ្រពីប្រជាពលរដ្ឋផង និងដើម្បីធ្វើឲ្យការអនុវត្តកម្មវិធីនយោបាយរបស់ខ្លួនបានជោគជ័យផង ក្រោយការបានទទួលសំឡេងគាំទ្រគ្រប់គ្រាន់ពីប្រជាពលរដ្ឋទៅបង្កើតរដ្ឋាភិបាល។

នយោបាយត្រូវតែធ្វើឡើងដោយប្រជាពលរដ្ឋគំរូក្នុងសង្គមដែលមានទស្សនវិស័យមុតស្រួចសម្រាប់ដោះស្រាយបញ្ហាសង្គម និងត្រូវបំពេញកិច្ចការនយោបាយដោយការលះបង់។

## ១. នយោបាយគឺជាសកម្មភាពលះបង់ដោយបេះដូងជួយសង្គ្រោះ

គ្រប់អ្នកនយោបាយគួរតែមកចូលរួមក្នុងសកម្មភាពនយោបាយរបស់ខ្លួនដោយការស្ម័គ្រចិត្ត និងដោយគ្មានការអំពាវនាវ អង្វរករពីប្រជាពលរដ្ឋ។ អ្នកនយោបាយនៅទីនេះសំដៅទៅដល់អ្នកដែលបានកាន់កិច្ចការស្រុកទេស តាមរយៈការបោះឆ្នោត ឬតាមរយៈការតែងតាំងសកម្មជនសំខាន់នៅក្នុងគណបក្សផ្សេងទៀត រួមទាំងគណបក្សប្រឆាំងដែលនឹងអាចត្រូវទៅកាន់ការងារស្រុកទេសតាមរយៈការបោះឆ្នោត ឬការតែងតាំងនាពេលអនាគត។ ច្រកដែលប្រជាពលរដ្ឋអាចក្លាយជាអ្នកនយោបាយ គឺតាមរយៈការចូលរួមសកម្មភាពជាមួយគណបក្សនយោបាយ។

ដោយសារការចូលធ្វើនយោបាយគឺជាទង្វើជួយសង្គ្រោះ ដែលគ្មានការបង្ខិតបង្ខំ និងជាទង្វើដែលទទួលបានការទុកចិត្តពីប្រជាពលរដ្ឋតាមរយៈសន្លឹកឆ្នោត ឬការតែងតាំងពីមេគណបក្សតាមរយៈជំនឿទុកចិត្ត អ្នកនយោបាយ ត្រូវតែមានបេះដូងសុចរិត និយាយតែការពិតអំពីទស្សនវិស័យនៃសកម្មភាពនយោបាយរបស់ខ្លួន។ ទុច្ចរិតភាពរបស់អ្នកនយោបាយតាមកាយក្តី វាចាក្តី និងចិត្តក្តីគឺជាការបោកប្រាស់ដែលមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរបំផុតចំពោះប្រជាពលរដ្ឋ និងចំពោះប្រទេសជាតិទាំងមូល។

## ២. នយោបាយគឺជាសកម្មភាពរបស់ជនគំរូក្នុងសង្គម

អ្នកនយោបាយត្រូវតែជាជនគំរូនៅក្នុងគ្រួសារ សហគមន៍ និងប្រទេសជាតិទាំងមូល។ ទោះបីជាគ្មានមនុស្សល្អឥតខ្ចោះក្នុងសង្គមក៏ដោយ ក៏អ្នកនយោបាយត្រូវតែជាអ្នកដែលមានគុណសម្បត្តិច្រើនជាង និងមានគុណវិបត្តិតិចជាងគេ បើប្រៀបធៀបទៅនឹងមនុស្សផ្សេងៗទៀត នៅក្នុងស្ថាប័ន ឬមូលដ្ឋាននោះ។ ជនណាម្នាក់អាចក្លាយជាជនគំរូដើម្បីចូលរួមក្នុងសកម្មភាពនយោបាយ ទាល់តែជននោះមានលក្ខណសម្បត្តិដូចខាងក្រោមក្នុងផ្នែកធនធានមនុស្សក្នុងឯកសារនេះ។

ជនគំរូក្នុងកិច្ចការនយោបាយដែលត្រូវដោះស្រាយបញ្ហាសង្គមខ្មែរ នាពេលបច្ចុប្បន្ននេះ ហើយត្រូវបានគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យឲ្យតម្លៃខ្ពស់បំផុត គឺអ្នកដែលមានបេះដូងសុចរិតជួយសង្គ្រោះជាតិផង និងអ្នកដែលមានចំណេះដឹងទូទៅស្តីពីបញ្ហាសង្គម និងជីវិតផង។ ប្រជាពលរដ្ឋដែលមានលក្ខណៈសម្បត្តិទាំងពីរនេះមិនចាំបាច់ទាល់តែអ្នកមានកម្រិតវប្បធម៌បច្ចេកទេសខ្ពស់រហូត

ដល់ថ្នាក់អនុបណ្ឌិត ឬបណ្ឌិតនោះទេ។ ជាការពិតណាស់ លក្ខណវិនិច្ឆ័យទាំងពីរនេះមានលក្ខណៈអរូបីយខ្លាំងណាស់ ហើយមិនអាចវាយតម្លៃដោយប្រជាពលរដ្ឋទូទៅ តាមរយៈពាក្យសម្ដី និងសកម្មភាពរបស់អ្នកនយោបាយនោះទេ។ អ្នកនយោបាយទាំងអ្នកសុចរិត និងអ្នកទុច្ចរិតអាចជាអ្នកពូកែនិយាយ និងមានសកម្មភាពហាក់បីដូចជាជួយ សង្គ្រោះដូចគ្នា។ ប៉ុន្តែព្រះពុទ្ធមានពុទ្ធដីកាថា "មនោបុព្វង្គមាធម្មា" (ចិត្តគឺជាអ្នកបញ្ជាសកម្មភាពតាមកាយ និងវាចា)។

ជនគំរូគឺជាជនដែលមិនប្រព្រឹត្តអំពើអាក្រក់ និងជាអ្នកធ្វើតែអំពើល្អ។ អំពើល្អក្នុងន័យនេះគឺជា "អំពើចាគៈប្រាសចាកភាពអាត្មានិយម និងប្រកបដោយការយល់ដឹង"។ លក្ខណសម្បត្តិសម្គាល់ជនគំរូគឺជាអ្នកដែលវៀរចាកមិនប្រព្រឹត្តអំពើដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួន ឬប្រព្រឹត្តក្នុងកម្រិតតិចតួចបំផុត បើប្រៀបធៀបទៅនឹងមនុស្សក្នុងសហគមន៍របស់គាត់។

ដោយមូលហេតុនេះ អ្នកនយោបាយត្រូវមានបេះដូងបរិសុទ្ធ និងមានទស្សនវិស័យមុតស្រួចបាញ់ឆ្ពោះទៅរកការពន្យល់ប្រជាពលរដ្ឋដើម្បីឲ្យពួកគាត់មានមូលដ្ឋានគ្រប់គ្រាន់ទៅរើសអ្នកនយោបាយដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់មកកាន់ការងារប្រទេសជាតិ។ ប្រជាពលរដ្ឋបែបណារើសបានអ្នកដឹកនាំបែបនោះ។ នៅក្នុងបរិបទកម្ពុជានាពេលនេះ ប្រជាពលរដ្ឋបានបាត់បង់ជំនឿទុកចិត្តទៅលើអ្នកនយោបាយផង និងទៅលើប្រជាពលរដ្ឋផងគ្នាជាទូទៅផង។ ការបាត់បង់ការជឿជាក់លើគ្នាទៅវិញទៅមកនេះគឺជាមហាគ្រោះថ្នាក់ចំពោះប្រជាពលរដ្ឋខ្លួនឯងផង ក៏ដូចចំពោះប្រទេសជាតិទាំងមូលផង។ ការធ្វើនយោបាយដោយសុចរិតដើម្បីស្ដារការជឿទុកចិត្តទៅលើអ្នកនយោបាយ គឺជាវិធីសាស្ត្រដ៏មាន

ប្រសិទ្ធភាពបំផុតដើម្បីស្តារការជឿទុកចិត្តគ្នា ក្នុងចំណោមប្រជាពលរដ្ឋដើម្បីបង្កើតជាកម្លាំងសាមគ្គីជាតិមួយដ៏រឹងមាំ។

## ៣. នយោបាយគឺជាសកម្មភាពប្រកួតប្រជែងទស្សនៈដឹកនាំដោយតម្លាភាព

សកម្មភាពនយោបាយ គឺជាសកម្មភាពផ្តើមចេញពីមនុស្សមួយក្រុមតូចក៏ពិតមែន ប៉ុន្តែវាជាសកម្មភាពដែលកំណត់ជោគវាសនាប្រទេសជាតិ និងប្រជាពលរដ្ឋទាំងមូល ជាពិសេសក្នុងកាលៈទេសៈបច្ចុប្បន្ននេះ។ បើធ្វើត្រូវទំនង វាអាចនាំឲ្យជាតិរីកចម្រើន និងគង់វង្ស។ បើធ្វើខុសទំនង វាអាចនាំឲ្យជាតិអន្តរាយ ឬបាត់បង់ជាតិសាសន៍ និងទឹកដីតែម្តង។

ដោយសារសកម្មភាពនយោបាយ ត្រូវប្រឈមមុខនឹងស្ថានភាពបែបនេះទើបវាគ្មានហេតុផលអ្វីដែលគណបក្សនយោបាយត្រូវលាក់លៀមអំពីសកម្មភាពនៃការធ្វើនយោបាយរបស់ខ្លួននោះទេ។ គណបក្សទាំងអស់ រួមទាំងគណបក្សកាន់អំណាចផងគួរតែបង្កលក្ខណៈងាយស្រួលឲ្យគណបក្សផ្សេងៗទៀតអាចបង្ហាញទស្សនវិស័យនៃការធ្វើនយោបាយរបស់ខ្លួនទៅដល់ប្រជាពលរដ្ឋ ដែលជាម្ចាស់ប្រទេសឲ្យបានទូលំទូលាយជាប់ជាប្រចាំ។

ការផ្តល់ឱកាសឲ្យគណបក្សផ្សេងៗធ្វើនយោបាយ ដោយតម្លាភាពតាមរយៈការបង្ហាញប្រជាពលរដ្ឋអំពីខ្លឹមសារគោលនយោបាយ និងរបៀបដែលគណបក្សទាំងនោះផ្សព្វផ្សាយដើម្បីគៀងគរប្រជាពលរដ្ឋឲ្យគាំទ្រខ្លួន គឺជាការចាំបាច់ដើម្បីឲ្យប្រជាពលរដ្ឋទទួលខុសត្រូវចំពោះជោគវាសនាប្រទេសជាតិ នៅពេលប្រជាពលរដ្ឋបោះឆ្នោតគាំទ្រ និងដើម្បីធានាសមភាពនៃការតទល់គ្នារវាងគណបក្សនិងគណបក្ស ដូចដែលបានធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់។

តម្លាភាពគឺជាធាតុផ្សំចាំបាច់ដើម្បីទប់ស្កាត់មនុស្សទុច្ចរិតមិនឲ្យចូលប្រឡូកក្នុងនយោបាយផង និងដើម្បីជាមធ្យោបាយឲ្យប្រជាពលរដ្ឋអាចវាយតម្លៃថាតើអ្នកណាជាអ្នកមានបេះដូងសុចរិត និងជាជនគំរូដែលសក្តិសមនឹងធ្វើជាតំណាងពួកគាត់ទៅកាន់ការងារប្រទេសជាតិផង។

យន្តការដើម្បីធានាតម្លាភាពក្នុងសកម្មភាពនយោបាយ គឺការផ្សព្វផ្សាយការជជែកដេញដោលរវាងតំណាងគណបក្ស និងប្រជាពលរដ្ឋ ឬការជជែកដេញដោលរវាងគណបក្ស និងគណបក្សនៅតាមប្រព័ន្ធផ្សព្វផ្សាយ តាមរលកធាតុអាកាស តាមការបោះពុម្ព តាមបណ្តាញសង្គម ឬតាមវេទិកានានា។ គោលបំណងនៃការជជែកដេញដោលគឺដើម្បីស្វែងយល់អំពីខ្លឹមសារគោលនយោបាយរបស់គណបក្សផង និងដើម្បីស្ទង់មើលដួងចិត្តសុចរិត ឬទុច្ចរិតរបស់ប្រមុខដឹកនាំគណបក្សនយោបាយនោះផង។

ជាលទ្ធផលនៃសកម្មភាពប្រកបដោយតម្លាភាពរបស់គណបក្សនយោបាយ ប្រជាពលរដ្ឋអាចដឹងយ៉ាងច្បាស់អំពីគោលនយោបាយរបស់គណបក្សនីមួយៗ ដឹងអំពីគោលបំណងនៃការធ្វើនយោបាយរបស់អ្នកនយោបាយ និងអំពីគោលដៅដែលគណបក្សនោះចង់នាំប្រជាពលរដ្ឋទៅ។ ដោយការយល់ដឹង ប្រជាពលរដ្ឋទាំងអស់អាចធ្វើការសម្រេចជ្រើសរើសគណបក្សដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់។ នេះគឺជាបដិវត្តស៊ីជម្រៅ ផ្លាស់ប្តូរទម្លាប់ពីការបោះឆ្នោតដោយការដោះដូរ ការដឹងគុណ ការភ័យខ្លាច និងការអាណិតស្រលាញ់មកជាការបោះឆ្នោតដោយការយល់ដឹងច្បាស់លាស់ និងការទទួលខុសត្រូវ។

នយោបាយគឺជាសកម្មភាពនៃការប្រកួតប្រជែងទស្សនៈរវាងគណបក្សនយោបាយមួយជាមួយគណបក្សនយោបាយមួយ ឬច្រើនទៀតដោយមានប្រជាពលរដ្ឋជាអ្នកសម្រេចសេចក្តី តាមរយៈឆ្នោតមួយសន្លឹករបស់ពួកគាត់។ ក្នុងភាពជាម្ចាស់ប្រទេស ប្រជាពលរដ្ឋមានសិទ្ធិស្របច្បាប់ដើម្បីស្វែងយល់អំពីគណបក្សនយោបាយនីមួយៗ។ ដូច្នេះ គណបក្សនីមួយៗត្រូវធ្វើសកម្មភាពនយោបាយរបស់ខ្លួនដោយតម្លាភាពជាទីបំផុត ដើម្បីឲ្យប្រជាពលរដ្ឋអាចសម្រេចបោះឆ្នោតជ្រើសរើសដោយមានព័ត៌មានគ្រប់គ្រាន់។ រដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានគួរបង្កលក្ខណៈដើម្បីឲ្យដំណើរការប្រកួតប្រជែងទស្សនៈនយោបាយអាចប្រព្រឹត្តទៅបានដោយទូលំទូលាយ និងស្មើភាពគ្នា។

គណបក្សនយោបាយត្រូវតែចាប់ផ្តើមប្រកួតប្រជែងទស្សនៈនៃការធ្វើនយោបាយដោយការពិភាក្សាដេញដោល ដោយដួងចិត្តសុចរិត តម្លាភាព ការទទួលខុសត្រូវ និងផ្អែកលើផលប្រយោជន៍រួមដើម្បីចៀសវាងការប្រឈមមុខគ្នាដោយកម្លាំងបាយ ឬកម្លាំងចិត្តនៃការគុំគួន។ ផ្តើមចេញពីការប្រកួតប្រជែងទស្សនៈ គណបក្សនយោបាយទាំងអស់ពិតជាអាចធ្វើការជាមួយគ្នាបានដោយ "តម្កល់ផលប្រយោជន៍ប្រជាពលរដ្ឋ និងជាតិ" ធំជាងផលប្រយោជន៍គណបក្ស ឬផលប្រយោជន៍បុគ្គល។

សរុបមក ការធ្វើនយោបាយគឺជាសកម្មភាពរបស់មនុស្សដែលចងក្រងគ្នាជាក្រុមៗដែលមើលឃើញ និងកំណត់បញ្ហាសង្គមដូចគ្នា មានទស្សនវិស័យដោះស្រាយបញ្ហានោះដូចគ្នា មានសណ្តានជាអ្នកឈឺឆ្អាលជួយសង្គ្រោះអ្នកដទៃឲ្យរួចផុតពីបញ្ហាដោយប្រាសចាកភាពអាត្មានិយម ដោយការប្រើប្រាស់មនោគមវិជ្ជានៃការធ្វើនយោបាយខុសប្លែកពីគ្នា។ ផ្អែកលើការវិភាគនេះ គណ

បក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យចាត់ទុកថា សកម្មភាពពន្យល់ប្រជាពលរដ្ឋគឺជាសកម្មភាពនយោបាយអទិភាពចំពោះមុខដែលខ្លួនត្រូវធ្វើជាអចិន្ត្រៃយ៍។ សន្លឹកឆ្នោតបានមកពីអ្នកដែលមិនយល់អំពីទស្សនវិស័យនយោបាយរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គ្មានប្រយោជន៍អ្វីសម្រាប់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យទេ ហើយមនុស្សនៅក្នុងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យក៏គ្មានតម្លៃអ្វីដែរសម្រាប់អ្នក ដែលមិនយល់អំពីទស្សនវិស័យនយោបាយរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។

ទស្សនវិស័យនៃការធ្វើនយោបាយ របស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ និងឆ្នោតមួយ សន្លឹកដែលទម្លាក់ចូលក្នុងហិបឆ្នោត ដោយការយល់ដឹងទើបមានតម្លៃសម្រាប់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យផង និងសម្រាប់ប្រជាពលរដ្ឋក្នុងចលនារំដោះខ្លួនឲ្យរួចផុតពីបញ្ហា និងការបាត់បង់ជាតិសាសន៍ និងទឹកដីផង។ ដូច្នេះ ប្រជាពលរដ្ឋត្រូវតែមានការយល់ដឹងអំពីទស្សនវិស័យរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យជាមុនសិន ទើបពួកគាត់មានសទ្ធាជ្រះថ្លាគាំទ្រទស្សនៈនេះ ហើយចាត់ទុកទស្សនៈនេះជារបស់ពួកគាត់ ឯសន្លឹកឆ្នោតគ្រាន់តែជាអានិសង្សដែលបានមកពីទង្វើនៃការពន្យល់របស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យតែប៉ុណ្ណោះ។

គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យប្រកាន់ខ្ជាប់ជានិច្ចទាំងទិសស្លោកដែល ថា "ដាក់ខ្លួនឲ្យទាប ឫកពាឲ្យសុភាព តែការងារឲ្យណាស់" ទាំងមនោគមវិជ្ជាដែលថា "យើងបង្កើតគណបក្សនេះឡើងដើម្បីជាតិ និងមិនយកប្រយោជន៍ជាតិដើម្បី

គណបក្សឡើយ” និងទាំងពុទ្ធដីកាថា “ពាលោអបរិយនាយកោ” (បុគ្គលពាល មិនត្រូវធ្វើនយោបាយទេ)។

## ៤
# ធនធានមនុស្ស

ដូចបានរៀបរាប់ខាងលើរួចមកហើយថា ប្រជាពលរដ្ឋកម្ពុជាបានចាត់ទុកនយោបាយ គឺជាកិច្ចការរបស់អ្នកនយោបាយ ហើយពួកគាត់បានអប់រំ និងជាទូទៅ ពួកគាត់បំបិទសិទ្ធិសេរីភាពកូនចៅគាត់ មិនឲ្យចូលរួមក្នុងសកម្មភាពនយោបាយ។ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យយល់ឃើញផ្ទុយពីនេះ ហើយចាត់ទុកប្រជាពលរដ្ឋគ្រប់រូបគឺជាកម្លាំងមិនអាចខ្វះបាន ដើម្បីរុញច្រានចលនានយោបាយឲ្យបានដល់គោលដៅ។ ដើម្បីឈានទៅសម្រេចគោលដៅខាងលើ កម្លាំងស្នូលរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យគឺជាអ្នកដែលយល់ដឹងអំពីតម្លៃពិតប្រាកដនៃជីវិត ហើយមានបេះដូងជាអ្នកជួយសង្គ្រោះអ្នកដទៃដោយប្រាសចាកភាពអាត្មានិយមផង និងយល់ដឹងច្បាស់លាស់អំពីអត្តសញ្ញាណសម្គាល់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតយ្យទាំងបួនផង និងមានការឃ្លោ ចិត្តខ្ពស់ដើម្បីចូលរួមប្រែក្លាយសុបិនរួមនៃការបង្កើតមាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់ឲ្យទៅជាការពិតផង។

ជាទូទៅ ធនធានមនុស្សដែលជាកម្លាំងស្នូលរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គឺជាអ្នកដែល ៖

- មើលឃើញបញ្ហាស្រុកទេស ប្រកពបញ្ហា និងដំណោះស្រាយបញ្ហាដូចគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ
- គាំទ្រយន្តការប្រាំបីចំណុច ហើយប្តេជ្ញាប្រែក្លាយយន្តការប្រាំបីចំណុ ចឲ្យទៅជាច្បាប់សម្រាប់អនុវត្តនៅកម្ពុជា

- ចូលរួមធ្វើឲ្យមានការដឹកនាំប្រទេសជាតិដោយប្រព័ន្ធច្បាប់ដែលគ្មានប្រជាពលរដ្ឋណាម្នាក់ រួមទាំងនាយករដ្ឋមន្ត្រីអាចនៅពីលើច្បាប់បាន

- ឃ្លោ គាំទ្រការប្រើប្រាស់ទាំងបេះដូងសុចរិតទៀងត្រង់ ទាំងទស្សនវិស័យដើម្បីកៀងគរកម្លាំងប្រជាពលរដ្ឋឲ្យចូលរួមក្នុងសកម្មភាពនយោបាយដោយការយល់ដឹងច្បាស់លាស់

- ឃ្លោ ចាត់ទុកនយោបាយជារឿងរបស់ប្រជាពលរដ្ឋគ្រប់រូបដែលត្រូវចូលរួមដោយការលះបង់ដើម្បីបុព្វហេតុរួម

- ជ្រោមជ្រែងទស្សនវិស័យរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យដែលចាត់ទុកតួនាទីក្នុងនយោបាយជាការលះបង់ទាំងកម្លាំងកាយចំណេះដឹង និងថវិកា និងមិនមែនជាមុខរបរចិញ្ចឹមជីវិតនោះទេ

- ប្រកាន់យកមេរៀនព្រះពុទ្ធ ត្រង់ចំណុចពាក់ព័ន្ធនឹងជីវិតបច្ចុប្បន្នមកបដិបត្តិទាំងសម្រាប់ការរស់នៅប្រចាំថ្ងៃ និងទាំងសម្រាប់ការធ្វើនយោបាយ

- ស្តើងលោកធម៌ទាំងប្រាំបីដែលជាប្រភពបណ្តាលឲ្យអ្នកនយោបាយមានបេះដូងមិនស្មោះត្រង់ចំពោះសកម្មភាពនយោបាយរបស់ខ្លួន គឺលាភ (អលាភ) យស(អយស) សរសើរ(និន្ទា) និងសុខ(ទុក្ខ)

- គាំទ្រការលុបបំបាត់ឥទ្ធិពលគណបក្សនយោបាយ ក្នុងជីវិតរស់នៅជាធម្មតារបស់ប្រជាជន និង/ឬមន្ត្រីរាជការដើម្បីចៀសវាងការចោទប្រកាន់គ្នា ឬការប្រព្រឹត្តដោយអយុត្តិធម៌ចំពោះគ្នាទៅវិញទៅមកយល់ដឹងយ៉ាងច្បាស់ថា មានតែការដឹកនាំដោយប្រព័ន្ធពង្រាយអំណាចទេ ទើបកម្ពុជាអាចដោះស្រាយបញ្ហាសព្វបែបយ៉ាងបាន និងចង់

បន្សល់ទុកមរតកនៃការដឹកនាំស្រុកទេស តាមប្រព័ន្ធប្រជាធិបតេយ្យ សម្រាប់កូនចៅជំនាន់ក្រោយៗទៀត

- ពិសេសបំផុតនោះ មានភាពច្បាស់លាស់ក្នុងចិត្តថា ខ្លួនចូលរួមធ្វើនយោបាយជាមួយគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យដោយគ្មានចង់បានអ្វីជាប្រយោជន៍ផ្ទាល់ខ្លួនទាល់តែសោះ

*ការបកស្រាយលម្អិតនៃចំណុចនីមួយៗខាងលើនេះ មាននៅក្នុងសារសំឡេងដែលអាចរកបាននៅទីស្នាក់ការ ឬគេហទំព័រគណបក្សសម្ព័ន្ធដើម្បីប្រជាធិតេយ្យ។*

ដោយហេតុថា គោលដៅនៃសកម្មភាពនយោបាយរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យគឺការកសាងមាតុភូមិមួយ ដែលប្រជាពលរដ្ឋអាចរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់នោះ ទើបការសម្រិតសម្រាំងកម្លាំងស្នូលចេញពីក្នុងចំណោម ប្រជាពលរដ្ឋទូទៅដែលមានការយល់ដឹងច្បាស់លាស់អំពីអត្តសញ្ញាណរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យពោល គឺគោលដៅ ចំណុចចាប់ផ្តើមឥរិយាបថនយោបាយ និងធនធានមនុស្សគឺជាកត្តាកំណត់ជោគជ័យរបស់ខ្លួន។ គោលធំៗ ទាំងបីដែលគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យបាន និងកំពុងធ្វើការពន្យល់ គឺជាមេរៀនសម្រាប់ប្រែក្លាយប្រជាពលរដ្ឋទូទៅឲ្យទៅជាប្រជាពលរដ្ឋខ្លឹម មានចរិតថ្លៃថ្នូរ និងមានការទទួលខុសត្រូវ។

ប្រជាពលរដ្ឋណា ដែលមានការយល់ដឹងច្បាស់លាស់អំពីគោលធំៗទាំងបីរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ហើយមានការរម្តៀ ចិត្តខ្ពស់ចង់ឃើញប្រទេសកម្ពុជាមានប្រជាពលរដ្ឋរស់នៅដោយសេចក្តីថ្លៃថ្នូរ ទាំងលោកសម្ភារៈ

សីលធម៌សង្គម និងចង់ឃើញកម្ពុជាជានីតិរដ្ឋពិតប្រាកដ ស្មើមុខស្មើមាត់នឹងបណ្ដាប្រទេសជឿនលឿនលើពិភពលោកនឹងមកចូលរួមជាកម្លាំងស្នូល ក្នុងគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យដើម្បីរុញច្រានឲ្យចលនានយោបាយដែលឈរលើបាតគ្រឹះសុចរិតនេះរីកដុះដាលនៅក្នុងសង្គមកម្ពុជា។

ដោយផ្អែកលើគោលដៅ ចំណុចចាប់ផ្ដើម ឥរិយាបថនយោបាយ និងធនធានមនុស្សរបស់ខ្លួន គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យគ្រាន់តែជាឈ្មោះគណបក្សនយោបាយមួយប៉ុណ្ណោះ។ របៀបនៃការគ្រប់គ្រង ការដឹកនាំ និងការចូលរួមតាំងពីពេលចាប់ផ្ដើមរហូតមកដល់ពេលនេះបង្ហាញយ៉ាងច្បាស់ថាគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យគ្មានម្ចាស់ណាក្រៅអំពីប្រជាពលរដ្ឋខ្លួនឯងនោះទេ។

នៅគ្រប់ពេលទាំងអស់ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យគឺជាគណបក្សរបស់ប្រជាពលរដ្ឋ បង្កើតឡើងដោយប្រជាពលរដ្ឋ និងដើម្បីប្រជាពលរដ្ឋដែលស្រលាញ់អំពើល្អ ហើយរួមគ្នាដេញកម្ចាត់អំពើអាក្រក់ពីសង្គមកម្ពុជា។ នៅពេលរបបគ្រប់គ្រងដែលប្រជាពលរដ្ឋគ្រប់រូបរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់កើតមាននៅលើទឹកដីសុវណ្ណភូមិរបស់យើងហើយ អ្នកដែលឈ្នះពិតប្រាកដគឺប្រជាពលរដ្ឋខ្មែរគ្រប់រូបមកពីគ្រប់និន្នាការនយោបាយ។

ពីចំណុចចាប់ផ្ដើមនៃការពន្យល់ប្រជាពលរដ្ឋឲ្យយល់ដឹង និងផ្លាស់ប្ដូរផ្នត់គំនិតលើគោលធំៗបី (នយោបាយ/ប្រជាធិបតេយ្យ កិច្ចបដិបត្តិព្រះធម៌ និងសីលធម៌សង្គម) រហូតបង្កើតបានមាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់គឺជាចម្ងាយមួយដែលប្រជាពលរដ្ឋខ្មែរទូទៅត្រូវដើរ

និងដែលកំពុងនាំមុខដោយគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។ ផ្អែកលើតារាងសង្ខេបសកម្មភាពខាងក្រោមនេះគឺជាដំណើរដែលមានផែនការច្បាស់លាស់ ប្រាកដនិយម ល្អិតល្អន់ និងអាចធ្វើទៅបាន។ អ្វីដែលប្រជាពលរដ្ឋត្រូវធ្វើនៅពេលនេះគឺការចូលរួមតាមគ្រប់រូបភាព និងលទ្ធភាពរបស់ខ្លួនម្នាក់ៗដោយការស្ម័គ្រចិត្ត និងការទទួលខុសត្រូវ ប្រាសចាកភាពអាត្មានិយម ស្របតាមគតិបណ្ឌិតរបស់ប្រធានាធិបតីសហរដ្ឋអាមេរិក ចន កេនេឌី(John F. Kennedy) ដែលថា "កុំសួរថាប្រទេសអ្នកបានផ្តល់អ្វីដល់អ្នក ប៉ុន្តែត្រូវសួរថាអ្នកបានធ្វើអ្វីខ្លះហើយសម្រាប់ប្រទេសរបស់អ្នក"។

"រួមគិត រួមធ្វើ រួមទទួលខុសត្រូវ ដើម្បីប្រែក្លាយកម្ពុជាឲ្យទៅជាមាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់"តាមរយៈសកម្មភាពជាក់លាក់ដូចខាងក្រោម៖

តារាងសង្ខេបសកម្មភាពរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ

**មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់**

**>>>**គឺជាគោលដៅរបស់គ.ស.ប

៦

ដើម្បីឲ្យកម្ពុជាក្លាយជាមាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នា ក្នុងភាពជាម្ចាស់**>>>ការកាត់បន្ថយអំណាចរដ្ឋ**គឺជាវិធានការមានប្រសិទ្ធភាព

៥

ដើម្បីឲ្យមានការកាត់បន្ថយអំណាចរដ្ឋ**>>>ការប្រែក្លាយយន្តការប្រាំបី ចំណុចឲ្យទៅជាច្បាប់**គឺជាលក្ខខណ្ឌចាំបាច់

៤

ដើម្បីប្រែក្លាយយន្តការប្រាំបីចំណុចឲ្យទៅជាច្បាប់**>>>ការចូលរួមរបស់ប្រជាពលរដ្ឋក្នុង សកម្មភាពនយោបាយជាមួយគ.ស.ប**គឺជាបដិវត្តផ្នត់គំនិតស៊ីជម្រៅ

៣

ដើម្បីឲ្យប្រជាពលរដ្ឋចូលរួមក្នុងសកម្មភាពនយោបាយជាមួយគ.ស.ប **>>>ការផ្លាស់ប្តូរផ្នត់គំនិតលើគោលធំៗ បី (ប្រជាធិបតេយ្យ កិច្ចបដិបត្តិព្រះធម៌ និងសីលធម៌សង្គម** )គឺជាបាតគ្រឹះ

២

ដើម្បីឲ្យប្រជាពលរដ្ឋផ្លាស់ប្តូរផ្នត់គំនិតលើគោលធំៗបី (ប្រជាធិបតេយ្យ កិច្ចបដិបត្តិព្រះធម៌ និងសីលធម៌សង្គម)

**>>>ការពន្យល់ប្រជាពលរដ្ឋ**គឺជាចំណុចចាប់ផ្តើម

១

ស្វែងយល់បន្ថែម

១. *វេទិកាតាមមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា*

២. *កម្មវិធីផ្សាយតាមវិទ្យុសំបុកឃ្មុំ*FM105 ៖ *ម៉ោង ២-៣ រសៀល*

៣. *គេហទំព័ររបស់ គ.ស.ប* ៖ www.camldp.org

៤. YouTube: *ខឹមវាសនា ឬ* Khem Veasna

៥. Paltalk: Koun Khmer Room

៦. Facebook: LDP Share ឬ Veasna Khem

៧. *សារអេឡិចត្រូនិក* ៖ camldp3@gmail.com


ដើម្បីមាតុភូមិមួយដែលពួកយើងរស់នៅ
ដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់
នាយករដ្ឋមន្ត្រីពីរអាណត្តិ
មិនអនុញ្ញាតឲ្យនាយករដ្ឋមន្ត្រីរើសកងអង្គរក្ស
នាយករដ្ឋមន្ត្រីរស់ក្នុងនិវេសនដ្ឋានរដ្ឋ
បង្កើតតុលាការរដ្ឋបាល
ឋានន្តរស័ក្តិចាប់ពីឧត្តមសេនីយ៍អនុម័តដោយសភា
អព្យាក្រឹតមន្ត្រីរាជការ
បោះឆ្នោតជ្រើសរើសតំណាងគ្រប់លំដាប់ថ្នាក់ដោយប្រជាពលរដ្ឋ
ប្រើប្រព័ន្ធបោះឆ្នោតចំមុខរើសតំណាងរាស្ត្រ
បំបែកប្រព័ន្ធដឹកនាំ
ដែលប្រមូលផ្ដុំអំណាច
តាមរយៈយន្តការ
8
ចំណុច